ព្រះរាជបញ្ញត្តិ

កាប្រកបកិច្ចការទូរគមនាគមន៍

ព.ស.២៥៤៤

---

ភូមិផុល អះឌុលលះយះដេជ

ធ្វើនៅថ្ងៃទី ៩ វិច្ឆិកា ព.ស.២៥៤៤

ជាឆ្នាំទី ៥៦ ក្នុងសម័យរជ្ជកាលបច្ចុប្បន្ន

ព្រះបាទសម្តេចព្រះប៉រះមិន្ទ មហាភូមិផុលអះឌុលលះយះឌេជ មានព្រះប្រមរាជឱង្ការអោយប្រកាសថា

ជាការគួរសមអោយមានច្បាប់ស្តីពីការប្រកបកិច្ចការទូរគមនាគមន៍

ព្រះរាជបញ្ញត្តិនេះមានបទបញ្ញត្តិប្រការខ្លះៗ ដែលកំណត់សិទ្ធិនិងសេរីភាពបុគ្គល ដែលមាត្រា ២៩ ប្រកបជាមួយមាត្រា ៣៤ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤៨ មាត្រា និងមាត្រា ៥០ របស់រដ្ឋធម្មនុញ្ញនៃរាជាណាចក្រថៃ បានចែងអោយប្រព្រឹត្តបាន ដោយអាស្រ័យអំណាចតាមបទបញ្ញត្តិនៃនិតិច្បាប់។

ទើបទ្រង់ព្រះករុណាអោយត្រាព្រះរាជបញ្ញត្តិតាមការណែនាំនិងឯកភាពពីរដ្ឋសភា ដូចតទៅ មាត្រា ១ ព្រះរាជបញ្ញត្តិនេះហៅថា "ព្រះរាជបញ្ញត្តិការប្រកបកិច្ចការទូរគមនាគមន៍ ព.ស.២៥៤៤"

មាត្រា ២ ព្រះរាជបញ្ញត្តិនេះចូលជាធរមានចាប់តាំងពីថ្ងៃដែលប្រកាសក្នុងព្រះរាជក្រម

មាត្រា ៣ អោយលុបចោល

(១) ព្រះរាជបញ្ញត្តិទូរលេខនិងទូរស័ព្ទ ព.ស.២៤៧៧

(២) ព្រះរាជបញ្ញត្តិទូរលេខនិងទូរស័ព្ទ(ច្បាប់ទី ២) ព.ស.២៥១៧

មាត្រា ៤ ក្នុងព្រះរាជបញ្ញត្តិនេះ

"កិច្ចការទូរគមនាគមន៍" មានន័យថា កិច្ចការទូរគមនាគមន៍តាមច្បាប់ស្តីពីអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំឡេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍

"ការប្រកបកិច្ចការទូរគមនាគមន៍" មានន័យថា ការប្រកបកិច្ចការក្នុងលក្ខណៈដែលជាការបំរើសេវាផ្នែកកិច្ចការទូរគមនាគមន៍ជូនបុគ្គលផ្សេងជាទូទៅ

"លេខទូរគមនាគមន៍" មានន័យថា តួលេខ អក្សរ ឬសញ្ញានានាដែលប្រើក្នុងការបញ្ជាក់គោលដៅក្នុងបណ្តាញទូរគមនាគមន៍ដើម្បីការទូរគមនាគមន៍

"បណ្តាញទូរគមនាគមន៍" មានន័យថា ក្រុមរបស់ម៉ាស៊ីនទូរគមនាគមន៍ដែលតភ្ជាប់គ្នាផ្ទាល់ឬតាមរយៈប្រព័ន្ធទូរសព្ទឬម៉ាស៊ីននានាដើម្បីជាការទូរគមនាគមន៍រវាងគោលដៅដែលកំណត់ជាមួយប្រព័ន្ធខ្សែ ប្រព័ន្ធរលកអាកាស ប្រព័ន្ធពន្លឺ ប្រព័ន្ធអេឡិចត្រូ ប្រព័ន្ធណាមួយឬច្រើនប្រព័ន្ធរួមគ្នា

"តភ្ជាប់" មានន័យថា ការតភ្ជាប់រវាងបណ្តាញទូរគមនាគមន៍ក្រោមការឯកភាពផ្នែកបច្ចេកទេសនិងផ្នែកពាណិជ្ជកម្មដើម្បីអោយអ្នកប្រើសេវារបស់អ្នកប្រកបកិច្ចការទូរគមនាគមន៍ភាគីមួយអាចទាក់ទងជាមួយអ្នកប្រើសេវាឬប្រើសេវាទូរគមនាគមន៍របស់អ្នកប្រកបកិច្ចការទូរគមនាគមន៍ភាគីមួយទៀតបាន

"គណៈកម្មការ" មានន័យថា គណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិតាមច្បាប់ស្តីពីអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំឡេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍

"ការិយាល័យ" មានន័យថា ការិយាល័យគណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិ

"លេខាធិការ" មានន័យថា លេខាធិការគណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិ

"មន្ត្រីសមត្ថកិច្ច" មានន័យថា អ្នកដែលគណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិ តែងតាំងអោយបំពេញទួនាទីតាមព្រះរាជបញ្ញត្តិនេះដោយប្រកាសក្នុងព្រះរាជក្រម

មាត្រា ៥ អោយនាយករដ្ឋមន្ត្រីជាអ្នកកាន់កាប់តាមព្រះរាជបញ្ញត្តិនេះ។

មាត្រា ៦ អោយគណៈកម្មការមានអំណាចតែងតាំងមន្ត្រីសមត្ថកិច្ចនិងចេញប្រកាសកំណត់កិច្ចការនានា ដើម្បីអនុវត្តតាមព្រះរាជបញ្ញត្តិនេះ

ប្រកាសនោះនៅពេលដែលប្រកាសក្នុងព្រះរាជក្រមហើយអោយចូលជាធរមាន

## ជំពូក ១
## ការអនុញ្ញាតប្រកបកិច្ចការទូរគមនាគមន៍

---

មាត្រា ៧ អ្នកណាមានបំណងចង់ប្រកបកិច្ចការទូរគមនាគមន៍តាមលក្ខណៈនិងប្រភេទដែលគណៈកម្មការប្រកាសកំណត់តាមច្បាប់ស្តីពីអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំឡេង វិទ្យុទូរទស្សន៍និងកិច្ចការទូរគមនាគមន៍ត្រូវបានប័ណ្ណអនុញ្ញាតពីគណៈកម្មការ

ប័ណ្ណប្រកបកិច្ចការទូរគមនាគមន៍មានបីប្រភេទ ដូចតទៅ

(១) ប័ណ្ណអនុញ្ញាតប្រភេទទីមួយ រួមមាន ប័ណ្ណអនុញ្ញាតសម្រាប់អ្នកប្រកបកិច្ចការទូរគមនាគមន៍ដែលមិនមានបណ្តាញទូរគមនាគមន៍ជារបស់ខ្លួនឯង និងជាកិច្ចការដែលមានលក្ខណៈគួរអោយមានការបំរើសេវាជាសេរី។ ទាំងនេះ នៅពេលដែលអ្នកមានបំណងនឹងប្រកបកិច្ចការបានជូនដំណឹងអោយគណៈកម្មការបានជ្រាបហើយ គណៈកម្មការត្រូវចេញប័ណ្ណអនុញ្ញាតអោយប្រកបកិច្ចការបាន

(២) ប័ណ្ណអនុញ្ញាតប្រភេទទីពីរ រួមមាន ប័ណ្ណអនុញ្ញាតសម្រាប់អ្នកប្រកបកិច្ចការទូរគមនាគមន៍ដែលមានឬមិនមានបណ្តាញជារបស់ខ្លួនឯង ដែលជាការប្រកបកិច្ចការដែលមានបំណងបំរើសេវាចំពោះក្រុមឬជាការប្រកបកិច្ចការដែលមិនមានផលប៉ះពាល់ចំពោះការប្រកួតប្រជែងដោយសេរី ឬចំពោះប្រយោជន៍សាធារណៈនិងអ្នកបរិភោគ។ ទាំងនេះ នៅពេលអ្នកដែលមានបំណងចង់ប្រកបកិច្ចការនោះបានអនុវត្តត្រឹមត្រូវគ្រប់គ្រាន់តាមគោលការណ៍ដែលគណៈកម្មការបានកំណត់ហើយ គណៈកម្មការត្រូវចេញប័ណ្ណអនុញ្ញាតអោយប្រកបកិច្ចការបាន

(៣) ប័ណ្ណអនុញ្ញាតប្រភេទទីបី រួមមាន ប័ណ្ណអនុញ្ញាតសម្រាប់អ្នកប្រកបកិច្ចការទូរគមនាគមន៍ដែលមានបណ្ដាញជារបស់ខ្លួនឯង ដែលជាការប្រកបកិច្ចការដែលមានបំណងបំរើសេវាជូនបុគ្គលទូទៅចំនួនច្រើន ឬអាចផលប៉ះពាល់ដល់ការប្រកួតប្រជែងដោយសេរី ឬអាចប៉ះពាល់ដល់ប្រយោជន៍ សាធារណៈ ឬមានមូលហេតុដែលត្រូវការពារអ្នកបរិភោគជាការពិសេស។ ទាំងនេះ នៅពេលអ្នកដែលមានបំណងចង់ប្រកបកិច្ចការនោះបានការពិចារណាពីគណៈកម្មការឃើញថាគួរចេញប័ណ្ណអនុញ្ញាត ទើបនឹងប្រកបកិច្ចការបាន។

អ្នកដែលបានប័ណ្ណអនុញ្ញាតប្រភេទទីមួយ ប្រភេទទីពីរ ឬប្រភេទទីបី នឹងមានសិទ្ធិប្រកបកិច្ចការទូរគមនាគមន៍ក្នុងលក្ខណៈឬប្រភេទណា រួមទាំងមានវិសាលភាពនៃការបំរើសេវាទ្រឹមណា អោយត្រូវទៅតាមដែលគណៈកម្មការបានប្រកាស ដែលត្រូវស្របទៅនឹងលក្ខណ្ឌការប្រកបកិច្ចការរបស់ប័ណ្ណអនុញ្ញាតប្រភេទនីមួយៗ ដែលកំណត់តាមកថាខណ្ឌទីពីរ និងត្រូវគិតអំពីការអភិវឌ្ឍការបំរើសេវាកិច្ចការទូរគមនាគមន៍ រួមទាំងភាពយុត្តិធម៌រវាងអ្នកប្រកបកិច្ចការផងដែរ។

ការចុះឈ្មោះសុំប័ណ្ណអនុញ្ញាត អ្នកសុំប័ណ្ណអនុញ្ញាតត្រូវបញ្ជាក់ថាជាការសុំប័ណ្ណអនុញ្ញាតប្រភេទណា រួមទាំងបញ្ជាក់លក្ខណៈឬប្រភេទកិច្ចការទូរគមនាគមន៍ដែលមានបំណងនឹងដំណើរការផងដែរ។ ហើយបើមានបំណងចង់បន្ថែមការប្រកបកិច្ចការក្នុងលក្ខណៈផ្សេងឬប្រភេទផ្សេងក្រោយពីបានការអនុញ្ញាតហើយ ត្រូវជូនដំណឹងអោយគណៈកម្មការបានជ្រាបមុនប្រកបកិច្ចការ ក្នុងករណីនេះ គណៈកម្មការនឹងកំណត់លក្ខណ្ឌអោយអ្នកសុំប័ណ្ណអនុញ្ញាតអនុវត្តក៏បានដែរ។

មាត្រា ៨ អោយគណៈកម្មការប្រកាសកំណត់លក្ខណ្ឌការអនុញ្ញាតអោយដឹងជាទូទៅ ដើម្បីអោយអ្នកដែលមានបំណងចង់ប្រកបកិច្ចការបានជ្រាបជាមុនទាក់ទងនិងលក្ខណៈសម្បត្តិរបស់អ្នកសុំប័ណ្ណអនុញ្ញាត វិធីការសុំប័ណ្ណអនុញ្ញាត និងលក្ខណ្ឌនៃការចេញប័ណ្ណអនុញ្ញាតដែលត្រូវកំណត់អោយខុសគ្នាតាមប្រភេទរបស់ប័ណ្ណអនុញ្ញាតតាមមាត្រា ៧ ហើយស្របទៅនឹងកិច្ចការទូរគមនាគមន៍លក្ខណៈមួយៗ និងប្រភេទនិងត្រូវស្របទៅតាមការអនុញ្ញាតអោយប្រើរលកអាកាស និងការអនុញ្ញាតអោយប្រកបកិច្ចការទូរគមនាគមន៍ដែលបានកំណត់ទុកក្នុងគម្រោងគំរូកិច្ចការទូរគមនាគមន៍និងគម្រោងរលកវិទ្យុតាមច្បាប់ស្ដីពីអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំឡេងវិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍។

ប្រកាសតាមកថាខណ្ឌទីមួយ អោយគណៈកម្មការកំណត់ពត៌មានទាក់ទងនឹងលក្ខណៈសម្បត្តិរបស់អ្នកសុំប័ណ្ណអនុញ្ញាត វិធីការសុំប័ណ្ណអនុញ្ញាត ឯកសារឬពត៌មានដែលចាំបាច់ក្នុងការអនុញ្ញាតវិធីការពិចារណានៃការចេញប័ណ្ណអនុញ្ញាត រយៈពេលនៃការពិចារណាអនុញ្ញាតរបស់គណៈកម្មការ វិសាលភាពនៃការអនុញ្ញាតអោយប្រកបកិច្ចការ ទំរង់ពេលច្រើនបំផុតនិងតិចបំផុតដែលនឹងអនុញ្ញាតអោយប្រកបកិច្ចការ រួមទាំងលក្ខណ្ឌនានាដែលចាំបាច់សម្រាប់ការប្រកបកិច្ចការ។

ក្នុងការកំណត់លក្ខណៈសម្បត្តិរបស់អ្នកសុំប័ណ្ណអនុញ្ញាតត្រូវស្របទៅតាមលក្ខណ្ឌដូចតទៅ

(១) អ្នកសុំប័ណ្ណអនុញ្ញាតប្រភេទទីពីរនិងអ្នកសុំប័ណ្ណអនុញ្ញាតប្រភេទទីបីត្រូវមិនមែនជនបុគ្គលអន្តោប្រវេសន៍តាមច្បាប់ស្ដីពីការប្រកបធុរកិច្ចរបស់ជនអន្តោប្រវេសន៍ និងត្រូវមានសមាមាត្រការកាន់ភាគហ៊ុនរបស់ជនដែលមានសញ្ជាតិថៃមិនតិចជាងចិតសិបប្រាំភាគរយរបស់ទុនទាំងអស់នៃសហគ្រាសនោះ។ រួមទាំងត្រូវមានកម្មការមិនតិចជាងបីភាគបួននៃចំនួនកម្មការទាំងអស់ និងអ្នកដែលមានអំណាចដំណើរការក្នុងសហគ្រាសនោះត្រូវជាជនដែលមានសញ្ជាតិថៃផងដែរ។ ក្នុងនេះ គណៈកម្មការអាចកំណត់អោយអ្នកសុំប័ណ្ណអនុញ្ញាតសម្រាប់ការប្រកបកិច្ចការលក្ខណៈខ្លះៗ ឬប្រភេទខ្លះដែលជាសហគ្រាសត្រូវកំណត់បំរាមការប្រព្រឹត្តិនានាដែលមានលក្ខណៈជាការបង្គប់កិច្ចការដោយជនដែលមិនមានសញ្ជាតិថៃក៏បានដែរ។

(២) មិនមែនជាជនក្ស័យធន

(៣) មិនធ្លាប់ត្រូវដកហូតប័ណ្ណអនុញ្ញាតប្រកបកិច្ចការទូរគមនាគមន៍

(៤) ជនដែលជាកម្មការ អ្នកគ្រប់គ្រងឬអ្នកដែលមានអំណាចក្នុងការគ្រប់គ្រងរបស់អ្នកសុំប័ណ្ណអនុញ្ញាត ត្រូវមិនធ្លាប់ត្រូវតុលាការកាត់ទោសថាមានកំហុសតាមព្រះរាជបញ្ញត្តិនេះ ឬតាមច្បាប់ស្តីពីទូរលេខនិងទូរស័ព្ទ ច្បាប់ស្តីពីវិទ្យុទូរគមនាគមន៍ ឬច្បាប់ស្តីពីការការពារអ្នកបរិភោគ ក្នុងរយៈពេលពីឆ្នាំមុនការដាក់ពាក្យសុំប័ណ្ណអនុញ្ញាត។

(៥) អ្នកសុំប័ណ្ណអនុញ្ញាតប្រភេទទីបីត្រូវមានគម្រោងការវិនិយោគនិងគម្រោងការអោយបំរើសេវាកិច្ចការទូរគមនាគមន៍ដែលអាចបំរើសេវាប្រកបទៅដោយប្រសិទ្ធិភាព។

(៦) មានលក្ខណៈសម្បត្តិនិងមិនមានលក្ខណៈសម្បត្តិត្រូវហាមឃាត់តាមដែលគណៈកម្មការកំណត់ សម្រាប់ការសុំប័ណ្ណអនុញ្ញាតប្រភេទនីមួយៗ តាមមាត្រា ៧

មាត្រា ៩ ការប្រកបកិច្ចការទូរគមនាគមន៍សម្រាប់ប័ណ្ណអនុញ្ញាតប្រភេទទីបី អោយមានរយៈពេលតាមដែលកំណត់ក្នុងប័ណ្ណអនុញ្ញាតដែលត្រូវស្របទៅនឹងរយៈពេលច្រើនបំផុតនិងតិចបំផុតតាមដែលគណៈកម្មការបានប្រកាសកំណត់។

ការសុំពន្យាប័ណ្ណអនុញ្ញាតសម្រាប់ប័ណ្ណអនុញ្ញាតប្រភេទទីបី អោយអ្នកសុំប័ណ្ណអនុញ្ញាតដាក់ពាក្យមុនថ្ងៃដែលប័ណ្ណអនុញ្ញាតផុតសុពលភាព។ នៅពេលដែលបានដាក់ពាក្យហើយ អោយចាត់ទុកថាអ្នកដែលដាក់ពាក្យមានឋានៈជាអ្នកបានប័ណ្ណអនុញ្ញាតលុះដល់មានបទបញ្ជាមិនអនុញ្ញាតអោយពន្យាប័ណ្ណអនុញ្ញាត។ ក៏ប៉ុន្តែ គណៈកម្មការត្រូវពិចារណានិងជូនដំណឹងបទបញ្ជាអោយអ្នកសុំប័ណ្ណអនុញ្ញាតបានជ្រាបក្នុងសាមសិបថ្ងៃចាប់ពីថ្ងៃដាក់ពាក្យ។

ការដាក់ពាក្យសុំពន្យាប័ណ្ណអនុញ្ញាតនិងការពន្យាប័ណ្ណអនុញ្ញាត អោយស្របទៅតាមគោលការណ៍ វិធីការ និងលក្ខណ្ឌដែលគណៈកម្មការបានកំណត់ដែលត្រូវស្របទៅតាមគោលការណ៍តាមមាត្រា ៨ ផងដែរ

ការកំណត់រយៈពេលនៃការអនុញ្ញាតនិងការពន្យាប័ណ្ណអនុញ្ញាត អោយគណៈកម្មការកំណត់ដោយគិតអំពីរយៈពេលតាមគម្រោងការវិនិយោគ វិសាលភាពការបំរើសេវា មធ្យោបាយការអភិវឌ្ឍកិច្ចការរបស់អ្នកសុំប័ណ្ណអនុញ្ញាត ការការពារអ្នកបរិភោគដែលនឹងទទួលបានការបំរើសេវាជាបន្តបន្ទាប់ និងមានលទ្ធផលការវាយតម្លៃការប្រកបកិច្ចការ។

ការប្រកបកិច្ចការទូរគមនាគមន៍ដែលបានប័ណ្ណអនុញ្ញាតប្រភេទទីមួយឬប័ណ្ណអនុញ្ញាតប្រភេទទីពីរ អោយអនុវត្តបានលុះត្រាដែលនៅបំរើសេវា ប៉ុន្តែនៅពេលដែលអ្នកបានប័ណ្ណអនុញ្ញាតមានបំណងចង់បញ្ឈប់កិច្ចការត្រូវជូនដំណឹងអោយគណៈកម្មការបានជ្រាបមុនមិនតិចជាមួយខែ។ ទាំងនេះ គណៈកម្មការអាចកំណត់លក្ខណ្ឌអោយអ្នកបានប័ណ្ណអនុញ្ញាតនោះត្រូវអនុវត្តមុននឹងបញ្ឈប់កិច្ចការក៏បានដែរ។

មាត្រា ១០ ការសុំប័ណ្ណអនុញ្ញាតប្រកបកិច្ចការទូរគមនាគមន៍ បើកិច្ចការទូរគមនាគមន៍នោះ មានការប្រើរលកអាកាស អ្នកសុំប័ណ្ណអនុញ្ញាតត្រូវបានការអនុញ្ញាតអោយប្រើរលកអាកាសតាមច្បាប់ស្តីពីអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំឡេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ផងដែរ។

ក្នុងករណីដែលអ្នកបានប័ណ្ណអនុញ្ញាតត្រូវដកហូតប័ណ្ណអនុញ្ញាតអោយប្រើរលកអាកាសមួយណា អោយចាត់ទុកថាត្រូវដកហូតប័ណ្ណអនុញ្ញាតប្រកបកិច្ចការទូរគមនាគមន៍ចំណែកដែលប្រកបកិច្ចការដោយប្រើរលកអាកាសផងដែរ។

មាត្រា ១១ អ្នកបានប័ណ្ណអនុញ្ញាតត្រូវបង់ថ្លៃការប្រើរលកអាកាស ថ្លៃលេខទូរគមនាគមន៍និងថ្លៃប័ណ្ណអនុញ្ញាតប្រកបកិច្ចការតាមអត្រា គោលការណ៍ និងវិធីការដែលគណៈកម្មការបានកំណត់។ ទាំងនេះ មិនត្រូវបង្កភាពលំបាកចំពោះអ្នកប្រកបកិច្ចការឬអ្នកប្រើសេវាដោយគ្មានហេតុផល។

ការកំណត់អត្រានិងគោលការណ៍នៃថ្លៃការប្រើរលកអាកាស និងថ្លៃលេខទូរគមនាគមន៍ អោយគណៈកម្មការគិតអំពីប្រយោជន៍សាធារណៈ ភាពជំណែញ ភាពខ្វះខាត និងវិធីការរៀបចំធនធាននោះ។

ការកំណត់អត្រានិងគោលការណ៍នៃអត្រាថ្លៃប័ណ្ណអនុញ្ញាតប្រកបកិច្ចការទូរគមនាគមន៍ អោយគណៈកម្មការគិតអំពីប្រភេទរបស់ប័ណ្ណអនុញ្ញាត ចំណាយនៃការគ្រប់គ្រងការប្រកបកិច្ចការទូរគមនាគមន៍ដែលកើតឡើងពីការអភិវឌ្ឍតាមព្រះរាជបញ្ញត្តិនេះ។

មាត្រា ១២ ការចេញប័ណ្ណអនុញ្ញាតសម្រាប់កិច្ចការទូរគមនាគមន៍ដែលត្រូវប្រើលេខទូរគមនាគមន៍តាមដែលកំណត់ក្នុងផែនលេខទូរគមនាគមន៍ អោយគណៈកម្មការកំណត់លេខទូរគមនាគមន៍សម្រាប់ប្រើក្នុងការបំរើសេវាឬតំបន់ការបំរើសេវាសម្រាប់ប្រកបកិច្ចការទូរគមនាគមន៍របស់អ្នកបានប័ណ្ណអនុញ្ញាតផងដែរ។

អ្នកបានប័ណ្ណអនុញ្ញាតនឹងនាំយកលេខទូរគមនាគមន៍ទៅបំរើសេវាជូនបុគ្គលជាទូទៅបានចំពោះលេខទូរគមនាគមន៍ដែលបានអនុញ្ញាតពីគណៈកម្មការ។

ក្នុងករណីដែលប្រាកដថាអ្នកបានប័ណ្ណអនុញ្ញាតមិនបាននាំយកលេខទូរគមនាគមន៍តាមដែលបានការអនុញ្ញាតចេញបំរើសេវាដោយមិនគួរសម ឬនាំលេខទូរគមនាគមន៍ដែលមិនបានការអនុញ្ញាតទៅបំរើសេវា អោយគណៈកម្មការមានអំណាចបញ្ជាអោយអ្នកបានប័ណ្ណអនុញ្ញាតដំណើរការអោយស្របទៅតាមការអនុញ្ញាតឬផ្អាកការប្រើលេខទូរគមនាគមន៍នោះបាន ដោយអ្នកបានប័ណ្ណអនុញ្ញាតមិនអាចបណ្តឹងទាមទារអ្វីបានឡើយ។

ក្នុងករណីដើម្បីការពារផលប្រយោជន៍របស់អ្នកប្រើសេវា និងនៅពេលដែលមានការរៀបចំផ្នែកបច្ចេកទេសរួចស្រេចហើយ។ អោយគណៈកម្មការកំណត់មធ្យោបាយនិងគោលការណ៍អោយអ្នកប្រើសេវាមានសិទ្ធិប្រើលេខទូរគមនាគមន៍ចាស់។ នៅពេលដែលអ្នកប្រើសេវាត្រូវការប្តូរអ្នកបំរើសេវា ទីកន្លែង ឬប្រភេទរបស់សេវា ទាំងនេះ អោយគណៈកម្មការរៀបចំអោយមានការស្តាប់មតិយោបល់ពីអ្នកបានប័ណ្ណអនុញ្ញាតដែលទាក់ទងផងដែរ។

ក្រោមបង្គាប់នៃយន្តការដែលគណៈកម្មការបានកំណត់មាត្រា ៥០ កថាខណ្ឌទីមួយ អោយអ្នកបានប័ណ្ណអនុញ្ញាតមានទូនាទីផ្តល់ពត៌មានអ្នកប្រើលេខទូរគមនាគមន៍ជូនបុគ្គលដែលសុំនាំយកទៅរៀបចំបង្កើតបញ្ជីរាយនាមអ្នកប្រើសេវា ដោយគិតថ្លៃបានចំពោះថ្លៃនៃការរៀបចំពត៌មានអោយប៉ុណ្ណោះ។

មាត្រា ១៣ ដើម្បីប្រយោជន៍នៃការកំណត់លេខទូរគមនាគមន៍ អោយអ្នកបានប័ណ្ណអនុញ្ញាតប្រើសម្រាប់បំរើសេវា ក្នុងការរៀបចំបង្កើតផែនការណ៍លេខទូរគមនាគមន៍របស់គណៈកម្មការតាមច្បាប់ស្តីពីអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំឡេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ត្រូវប្រកបទៅដោយគោលការណ៍ដូចតទៅ

(១) អោយមានលេខទូរគមនាគមន៍គ្រប់គ្រាន់ចំពោះការបំរើសេវា

(២) អោយមានការប្រើលេខទូរគមនាគមន៍ប្រកបទៅដោយប្រសិទ្ធិភាពនិងយុត្តិធម៌

(៣) ផែនការណ៍លេខទូរគមនាគមន៍ត្រូវជួយសម្រួលដល់ការបែងចែកលក្ខណៈនិងប្រភេទរបស់សេវានិងឧបករណ៍ដែលប្រើក្នុងកិច្ចការទូរគមនាគមន៍បានយ៉ាងងាយស្រួលនិងច្បាស់លាស់។

(៤) អោយមានការកែសម្រួលបន្ថែមផែនការណ៍លេខទូរគមនាគមន៍បានចំពោះករណីដែលមានការចំបាច់ប៉ុណ្ណោះ។

ក្នុងករណីដែលគណៈកម្មការកំណត់ផែនការណ៍លេខទូរគមនាគមន៍ឬអោយមានការកែសម្រួលបន្ថែមផែនការណ៍លេខទូរគមនាគមន៍មិនថាទាំងអស់ឬមួយចំណែក អោយអ្នកបានប័ណ្ណអនុញ្ញាតមានទូនាទីអនុវត្តតាមគោលការណ៍តាមដែលគណៈកម្មការបានកំណត់។

មាត្រា ១៤ ករណីដែលអ្នកបានប័ណ្ណអនុញ្ញាតមានបំណងនឹងសុំពង្រីកការបំរើសេវាដោយការបង្កើនចំនួនលេខទូរគមនាគមន៍សម្រាប់ប្រើក្នុងការបំរើសេវាឬការពង្រីកតំបន់បំរើសេវា អោយដាក់ពាក្យចំពោះគណៈកម្មការ។

ករណីដែលគណៈកម្មការឃើញថាការបង្កើនចំនួនលេខទូរគមនាគមន៍ឬការពង្រីកតំបន់អោយបំរើសេវានឹងមានប្រយោជន៍ចំពោះសាធារណៈ និងមិនមានលក្ខណៈជាការរាំងការប្រកួតប្រជែងក្នុងការប្រកបកិច្ចការទូរគមនាគមន៍ប្រកបទៅដោយភាពយុត្តិធម៌។ គណៈកម្មការអាចពិចារណាអនុញ្ញាតអោយអ្នកបានប័ណ្ណអនុញ្ញាតដំណើរការបានតាមគោលការណ៍និងលក្ខណ្ឌដែលគណៈកម្មការកំណត់។ ក្នុងនេះ អោយគណៈកម្មការពិចារណានិងជូនដំណឹងអោយអ្នកបានប័ណ្ណអនុញ្ញាតបានជ្រាប់ក្នុងសាមសិបថ្ងៃចាប់ពីថ្ងៃដែលបានទទួលពាក្យ និងក្នុងការអនុញ្ញាតអោយគណៈកម្មការទារថ្លៃការប្រកបកិច្ចការទូរគមនាគមន៍ក្នុងផ្នែកដែលបានអនុញ្ញាតនោះបន្ថែមតាមគោលការណ៍ដែលគណៈកម្មការកំណត់។

មាត្រា ១៥ ក្នុងការប្រកបកិច្ចការទូរគមនាគមន៍ អ្នកបានប័ណ្ណអនុញ្ញាតត្រូវអនុវត្តតាមគោលការណ៍ដែលបានកំណត់ក្នុងច្បាប់ស្ដីពីអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំឡេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ និងតាមលក្ខណ្ឌដែលគណៈកម្មការកំណត់។

ក្នុងការកំណត់លក្ខណ្ឌនៃការអនុញ្ញាត អោយគណៈកម្មការកំណត់សិទ្ធិអំណាចនិងការទទួលខុសត្រូវ ជាពិសេសរបស់អ្នកបានប័ណ្ណអនុញ្ញាតអោយបានច្បាស់លាស់។ រួមទាំងកំណត់ផែនការណ៍ការបំរើសេវាកិច្ចការទូរគមនាគមន៍របស់អ្នកបានប័ណ្ណអនុញ្ញាត។ ដោយយ៉ាងហោចណាស់ត្រូវកំណត់ដំណាក់កាលនិងរយៈពេលនៃការចាប់ផ្ដើមបំរើសេវា ពត៌មាននៃលក្ខណៈឬប្រភេទការបំរើសេវា អត្រាថ្លៃសេវា ការអោយសេវាជូនដំណឹងពត៌មានអ្នកប្រើលេខទូរគមនាគមន៍ និងការងារនានាដែលចាំបាច់ក្នុងការបំរើសេវាដើម្បីប្រយោជន៍ជាសាធារណៈ។

មាត្រា ១៦ ក្នុងករណីដែលអ្នកបានប័ណ្ណអនុញ្ញាតបានការអនុញ្ញាតអោយប្រកបកិច្ចការតាមលេខទូរគមនាគមន៍ឬតាមតំបន់ដែលកំណត់ បើប្រាកដចំពោះគណៈកម្មការថាអ្នកបានប័ណ្ណអនុញ្ញាតមិនដំណើរការតាមផែនការណ៍បំរើសេវេកិច្ចការទូរគមនាគមន៍ដែលកំណត់ជាលក្ខណ្ឌការអនុញ្ញាតតាមមាត្រា ១៥ ដោយគ្មានមូលហេតុគួរសម។ ហើយគណៈកម្មការឃើញថាជាការប៉ះពាល់ដល់ប្រយោជន៍សាធារណៈ។ អោយគណៈកម្មការមានអំណាចដកហូតលេខទូរគមនាគមន៍តាមចំនួនដែលកំណត់ ឬកំណត់តំបន់ការបំរើសេវាអោយតិចចុះពីដែលបានអនុញ្ញាតហើយ ដោយអ្នកបានប័ណ្ណអនុញ្ញាតមិនអាចបណ្ដឹងទាមទារអ្វីបានឡើយ។

មាត្រា ១៧ អោយគណៈកម្មការមានទូនាទីរៀបចំអោយមានការបំរើសេវាទូរគមនាគមន៍គ្រឹះយ៉ាងគ្រប់គ្រាន់ និងអោយមានអំណាចកំណត់អោយអ្នកបានប័ណ្ណអនុញ្ញាតត្រូវរៀបចំអោយមានបំរើសេវាទូរគមនាគមន៍ដូចតទៅ

(១) រៀបចំអោយមានសេវាទូរគមនាគមន៍ក្នុងតំបន់ជនបទ ឬតំបន់ដែលមានជំណៃញតិច ឬតំបន់មួយណាដែលមិនមានអ្នកបំរើសេវាឬមានប៉ុន្តែមិនគ្រប់គ្រាន់តាមតម្រូវការរបស់អ្នកប្រើសេវាក្នុងតំបន់នោះ។

(២) រៀបចំអោយមានសេវាទូរគមនាគមន៍សម្រាប់កន្លែងអប់រំ សាសនស្ថាន មន្ទីពេទ្យ និងអង្គការនានាដែលជំនួយដល់សង្គម។

(៣) រៀបចំអោយមានសេវាទូរគមនាគមន៍សាធារណៈលក្ខណៈខ្លះៗ ឬប្រភេទខ្លះៗ តាមដែលគណៈកម្មការបានកំណត់ចំពោះអ្នកមានប្រាក់ចំណូលតិច។

(៤) រៀបចំអោយមានសេវាសម្រួលក្នុងការប្រើសេវាទូរគមនាគមន៍សាធារណៈសម្រាប់ជនពិការ កុមារ មនុស្សចាស់ជរា និងជនដែលជួបការលំបាកក្នុងសង្គម។

គោលការណ៍ វិធីការ និងលក្ខណ្ឌនៃការកំណត់អោយអ្នកបានប័ណ្ណអនុញ្ញាតត្រូវរៀបចំអោយមានសេវាទូរគមនាគមន៍តាមកថាខណ្ឌទីមួយ អោយស្របទៅតាមដែលគណៈកម្មការបានកំណត់។

អោយគណៈកម្មការរៀបចំអោយមានការប្រកាសតាមកថាខណ្ឌទីពីរទុកជាមុនដើម្បីអោយអ្នកដែលមានបំណងចង់នឹងសុំប័ណ្ណអនុញ្ញាតបានជ្រាបទំរង់ការរៀបចំអោយមានសេវាទូរគមនាគមន៍តាមកថាខណ្ឌទីមួយមុនការដាក់ពាក្យសុំអនុញ្ញាត។

ការកំណត់អោយអ្នកបានប័ណ្ណអនុញ្ញាតរៀបចំអោយមានសេវាទូរគមនាគមន៍តាមមាត្រានេះត្រូវមិនបង្កអោយមានការលំបាកចំពោះអ្នកបានប័ណ្ណអនុញ្ញាត ហើយត្រូវអោយមានការអនុវត្តដោយសមភាពរវាងអ្នកបានប័ណ្ណអនុញ្ញាតដែលប្រកបកិច្ចការទូរគមនាគមន៍ក្នុងលក្ខណៈនិងប្រភេទដូចគ្នា។

មាត្រា ១៨ ក្នុងករណីដែលអ្នកបានប័ណ្ណអនុញ្ញាតមិនអាចរៀបចំអោយមានសេវាទូរគមនាគមន៍តាមដែលគណៈកម្មការកំណត់តាមមាត្រា ១៧ បាន ឬក្នុងករណីដែលឃើញថាជាការគួរសមអោយអ្នកបានប័ណ្ណអនុញ្ញាតរួមទទួលខុសត្រូវក្នុងការរៀបចំអោយមានសេវាទូរគមនាគមន៍ អោយគណៈកម្មការមានអំណាចកំណត់អោយអ្នកបានប័ណ្ណអនុញ្ញាតនោះត្រូវរៀបចំចំណូលដែលបានពីការបំរើសេវាទូរគមនាគមន៍ជូនមូលនិធិអភិវឌ្ឍកិច្ចការទូរគមនាគមន៍ដើម្បីប្រយោជន៍សាធារណៈតាមច្បាប់ស្តីពីអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំឡេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ដើម្បីនាំទៅដំណើរការរៀបចំអោយមានការបំរើសេវាទូរគមនាគមន៍តាមមាត្រា ១៧។

មាត្រា ១៩ អោយគណៈកម្មការមានអំណាចកំណត់យន្តការនានា ដើម្បីគាំទ្រនិងជំរុញអោយអ្នកបានប័ណ្ណអនុញ្ញាតថ្មីមានឱកាសបំរើសេវាទូរគមនាគមន៍ក្នុងតំបន់និងអាចប្រកួតប្រជែងជាមួយអ្នកបានប័ណ្ណអនុញ្ញាតផ្សេងៗបានប្រកបដោយប្រសិទ្ធិភាព សមភាពនិងយុត្តិធម៌។

មាត្រា ២០ អ្នកបានប័ណ្ណអនុញ្ញាតនិងផ្អាកឬបញ្ឈប់ការបំរើសេវាមិនថាទាំងអស់ឬមួយផ្នែកមិនបាន។ លើកលេងតែនិងបានការអនុញ្ញាតពីគណៈកម្មការតាមគោលការណ៍និងវិធីការដែលគណៈកម្មការបានកំណត់។

អ្នកបានប័ណ្ណអនុញ្ញាតនិងបដិសេធការបំរើសេវាចំពោះបុគ្គលមួយណាដោយគ្មានមូលហេតុបានឡើយ៩។

មាត្រា ២១ ការប្រកបកិច្ចការទូរគមនាគមន៍ ក្រៅពីត្រូវនៅក្រោមបង្គាប់របស់ច្បាប់ស្តីពីការប្រកួតប្រជែងផ្នែកពាណិជ្ជកម្មហើយអោយគណៈកម្មការកំណត់យន្តការតាមលក្ខណៈការប្រកបកិច្ចការទូរគមនាគមន៍មិនអោយអ្នកបានប័ណ្ណអនុញ្ញាតប្រព្រឹត្តិក្នុងលក្ខណៈជាការផ្តាច់មុខ ឬចុះថ្លៃ ឬកំណត់ការប្រកួតប្រជែងក្នុងការបំរើសេវាកិច្ចការទូរគមនាគមន៍ក្នុងរឿងដូចតទៅ

(១) ការជួយគាំទ្រការបំរើសេវា

(២) ការកាន់កាប់ធុរកិច្ចក្នុងបំរើសេវាប្រភេទជាមួយគ្នា

(៣) ការប្រើអំណាចដែលចំពោះទីផ្សារដែលមិនយុត្តិធម៌

(៤) អំពើរារាំងក្នុងការប្រកួតប្រជែង

(៥) ការការពារអ្នកវិនិយោគតូចៗ

មាត្រា ២២ អ្នកបានប័ណ្ណអនុញ្ញាតត្រូវរាយការណ៍អោយលេខាធិការជ្រាបជាបន្ទាន់នៅពេលដែលមានហេតុការណ៍ដូចតទៅ

(១) អ្នកបានប័ណ្ណអនុញ្ញាតរងការខូចខាតយ៉ាងធ្ងន់ធ្ងរដែលអាចបង្កអោយមានបញ្ហាចំពោះការបំរើសេវាទូរគមនាគមន៍

(២) អ្នកបានប័ណ្ណអនុញ្ញាតនឹងប្រកបកិច្ចការទូរគមនាគមន៍ផ្សេងពីបានការអនុញ្ញាត

(៣) អ្នកបានប័ណ្ណអនុញ្ញាតនឹងធ្វើកិច្ចសន្យាអោយបុគ្គលផ្សេងមានអំណាចទាំងស្រុងឬមួយចំណែកក្នុងការគ្រប់គ្រងការងាររបស់អ្នកបានប័ណ្ណអនុញ្ញាត

(៤) អ្នកបានប័ណ្ណអនុញ្ញាតប្រព្រឹត្តិឬរងការប្រព្រឹត្តិដែលមានលក្ខណៈជាការបង្គាប់កិច្ចការឬត្រូវបង្គាប់កិច្ចការតាមច្បាប់ស្តីពីទ្រព្យនិងផ្សារហ៊ុន

(៥) ករណីនានាដែលមានឬអាចមានផលប៉ះពាល់ចំពោះការប្រកបកិច្ចការឬការបំរើសេវារបស់អ្នកបានប័ណ្ណអនុញ្ញាតតាមដែលគណៈកម្មការបានកំណត់

ការរាយការណ៍តាម (២) និង (៣) អ្នកបានប័ណ្ណអនុញ្ញាតត្រូវអនុវត្តមុនដំណើរ រីឯករណីតាម (១) (៤) និង (៥) អោយរាយការណ៍ភ្លាមៗ ដែលមានហេតុការណ៍កើតឡើង។

នៅពេលដែលលេខាធិការបានទទួលរបាយការណ៍តាមកថាខណ្ឌទីពីរ អោយស្នើលិខិតជូនគណៈកម្មការជាបន្ទាន់ ក្នុងនេះអោយគណៈកម្មការមានអំណាចកំណត់លក្ខខណ្ឌអោយអ្នកបានប័ណ្ណអនុញ្ញាតត្រូវអនុវត្តយ៉ាងណាមួយដើម្បីការពារភាពខូចខាតចំពោះសាធារណៈបាន។

មាត្រា ២៣ គណៈកម្មការអាចកំណត់អោយអ្នកបានប័ណ្ណអនុញ្ញាតត្រូវរៀបចំអោយមានប្រព័ន្ធកត់ត្រាទិន្នន័យទាក់ទងនឹងការប្រើសេវាទូរគមនាគមន៍របស់អ្នកប្រើសេវាដើម្បីអោយអ្នកប្រើសេវាអាចត្រួចពិនិត្យបាន

មាត្រា ២៤ ក្នុងករណីដែលការប្រកបកិច្ចការទូរគមនាគមន៍លក្ខណៈខ្លះៗឬប្រភេទខ្លះៗ មានបច្ចេកទេសចំពោះផ្នែក ដែលមិនអាចនាំសេចក្តីក្នុងជំពូកនេះមកអនុវត្តអោយស្របទៅនឹងការប្រកបកិច្ចការទូរគមនាគមន៍នោះបាន។ អោយគណៈកម្មការមានអំណាចកំណត់លក្ខណ្ឌសម្រាប់ការប្រកបកិច្ចការទូរគមនាគមន៍តាមលក្ខណៈនិងប្រភេទរបស់កិច្ចការទូរគមនាគមន៍នោះបាន។

ការកំណត់លក្ខណ្ឌការប្រកបកិច្ចការទូរគមនាគមន៍តាមកថាខណ្ឌទីមួយត្រូវស្របទៅតាមដែលគណៈកម្មការបានកំណត់

## ជំពូក ២
## ការប្រើនិងតភ្ជាប់បណ្តាញទូរគមនាគមន៍

---

មាត្រា ២៥ អ្នកបានប័ណ្ណអនុញ្ញាតដែលមានបណ្តាញទូរគមនាគមន៍ មានទួនាទីអោយអ្នកបានប័ណ្ណអនុញ្ញាតផ្សេងៗ តភ្ជាប់បណ្តាញទូរគមនាគមន៍របស់ខ្លួនជាមួយនឹងអ្នកបានប័ណ្ណអនុញ្ញាតផ្សេងតាមគោលការណ៍និងវិធិការដែលគណៈកម្មការកំណត់។

អ្នកបានប័ណ្ណអនុញ្ញាតដែលមានបណ្តាញទូរគមនាគមន៍ត្រូវយល់ព្រមអោយអ្នកបានប័ណ្ណអនុញ្ញាតផ្សេងប្រើបណ្តាញទូរគមនាគមន៍របស់ខ្លួនតាមគោលការណ៍និងវិធិការដែលគណៈកម្មការកំណត់។

ការបដិសេធមិនអោយប្រើបណ្តាញទូរគមនាគមន៍ អោយអនុវត្តបានចំពោះករណីដូចតទៅ

(១) បណ្តាញទូរគមនាគមន៍ដែលមាននៅមិនគ្រប់គ្រាន់សម្រាប់ការអោយអ្នកបានប័ណ្ណអនុញ្ញាតផ្សេងប្រើបណ្តាញទូរគមនាគមន៍

(២) ការប្រើបណ្តាញទូរគមនាគមន៍មានបញ្ហាផ្នែកបច្ចេកទេសដែលអាចបង្កអោយមានការរំខានកិច្ចការទូរគមនាគមន៍ឬជាមូលហេតុរារាំងការទូរគមនាគមន៍

(៣) ករណីផ្សេងតាមដែលគណៈកម្មការបានកំណត់

អោយអ្នកបានប័ណ្ណអនុញ្ញាតដែលមានបណ្តាញទូរគមនាគមន៍ដែលបដិសេធមិនអោយប្រើបណ្តាញទូរគមនាគមន៍តាមកថាខណ្ឌទីបីមានទូនាទីបញ្ជាក់នៅមូលហេតុនៃការបដិសេធនោះ

ការទារថ្លៃឈ្នួលការប្រើឬការតភ្ជាប់បណ្តាញត្រូវមានភាពសមរួមនិងយុត្តិធម៌ចំពោះអ្នកបានប័ណ្ណអនុញ្ញាតដែលមានបណ្តាញទូរគមនាគមន៍និងអ្នកសុំប្រើឬតភ្ជាប់បណ្តាញទូរគមនាគមន៍និងត្រូវអោយមានភាពសមភាពរវាងអ្នកសុំប្រើឬអ្នកសុំភ្ជាប់បណ្តាញទូរគមនាគមន៍គ្រប់អ្នក។

ការកំណត់គោលការណ៍និងវិធីការតាមកថាខណ្ឌទីពីរ អោយគណៈកម្មការរៀបចំអោយមានការស្តាប់មតិពីអ្នកបានប័ណ្ណអនុញ្ញាតដែលទាក់ទងផងដែរ។

មាត្រា ២៦ ក្នុងករណីដែលមានការបដិសេធមិនអោយប្រើបណ្តាញទូរគមនាគមន៍ឬមានចំណុចដែលឯកភាពគ្នាមិនបានក្នុងចរចាធ្វើកិច្ចសន្យាប្រើឬភ្ជាប់បណ្តាញទូរគមនាគមន៍។ ដៃគូអាចមានសិទ្ធបណ្តឹងទាមទារអោយគណៈកម្មការពិចារណាកាត់ក្តីបានតាមគោលការណ៍និងវិធីការដែលគណៈកម្មការបានកំណត់ ការកាត់ក្តីរបស់គណៈកម្មការជាទីបញ្ចប់។

ក្នុងអំឡុងពេលដែលការពិចារណារបស់គណៈកម្មការតាមកថាខណ្ឌទីមួយ បើមានការចាំបាច់ គណៈកម្មការអាចបញ្ជាអោយប្រើឬភ្ជាប់បណ្តាញទូរគមនាគមន៍ជាបណ្តើរៗ តាមគោលការណ៍និងវិធីការដែលគណៈកម្មការបានកំណត់

មាត្រា ២៧ កិច្ចសន្យាទាក់ទងនឹងការប្រើឬភ្ជាប់បណ្តាញទូរគមនាគមន៍ត្រូវមានលក្ខណៈដូចតទៅ

(១) មិនធ្វើអោយអ្នកប្រើសេវាខូចខាតប្រយោជន៍

(២) មិនរើសអើង ឬរារាំងអ្នកបានប័ណ្ណអនុញ្ញាតផ្សេង

(៣) លក្ខណៈកំណត់ផ្នែកបច្ចេកទេស នៅចំណុចដែលមានការប្រើឬភ្ជាប់បណ្តាញទូរគមនាគមន៍ត្រូវច្បាស់លាស់ផ្នែកបច្ចេកទេសនិងមិនបង្កអោយមានផ្ទុកចំពោះអ្នកប្រើឬអ្នកភ្ជាប់បណ្តាញទូរគមនាគមន៍លើសពីការគួរសម។

(៤) មានការកំណត់ទូនាទីនិងការទទួលខុសត្រូវរបស់អ្នកប្រើ ឬអ្នកដែលសុំភ្ជាប់បណ្តាញទូរគមនាគមន៍និងអ្នកអោយប្រើឬអ្នកសុំភ្ជាប់បណ្តាញទូរគមនាគមន៍អោយបានច្បាស់លាស់

(៥) ការកំណត់អត្រាតម្លៃនៃការប្រើឬការភ្ជាប់បណ្តាញទូរគមនាគមន៍តាមគោលការណ៍ក្នុងមាត្រា ២៥ កថាខណ្ឌទីប្រាំ

(៦) លក្ខណៈផ្សេងៗតាមដែលគណៈកម្មការបានកំណត់

អោយអ្នកបានប័ណ្ណអនុញ្ញាតដែលជាម្ចាស់បណ្តាញទូរគមនាគមន៍ត្រូវបញ្ជូនច្បាប់ចម្លងនៃកិច្ចសន្យាទៅអោយគណៈកម្មការក្នុងដប់ថ្ងៃចាប់ពីថ្ងៃដែលមានការចុះហត្ថលេខាក្នុងកិច្ចសន្យា។ បើគណៈកម្មការឃើញថាលក្ខណ្ឌនៃកិច្ចសន្យានោះមិនស្របទៅតាមកថាខណ្ឌទីមួយ

អោយគណៈកម្មការមានអំណាចបញ្ជាអោយមានការកែសម្រួលក្នុងរយៈពេលដែលកំណត់។ បើអ្នកបានប័ណអនុញ្ញាតដែលជាម្ចាស់បណ្តាញទូរគមនាគមន៍មិនយល់ព្រមកែសម្រួលកិច្ចសន្យាអោយស្របទៅតាមដែលគណៈកម្មការបានកំណត់ទេ។ អោយនាំយកសេចក្តីក្នុងមាត្រា ៦៥ មកអនុវត្តជាការអនុលោម ប៉ុន្តែបើអ្នកសុំប្រើឬអ្នកសុំភ្ជាប់បណ្តាញទូរគមនាគមន៍ជាអ្នកមិនយល់ព្រមកែសម្រួលកិច្ចសន្យានោះ អោយចាត់ទុកថាកិច្ចសន្យានោះជាមោឃៈ

មាត្រា ២៨ អ្នកបានប័ណ្ណអនុញ្ញាតត្រូវជូនដំណឹងពត៌មានដ៏ត្រឹមត្រូវនិងចាំបាច់ក្នុងការប្រើឬភ្ជាប់បណ្តាញទូរគមនាគមន៍អោយអ្នកសុំប័ណ្ណអនុញ្ញាតផ្សេងៗដែលជាអ្នកសុំប្រើឬអ្នកសុំភ្ជាប់បណ្តាញទូរគមនាគមន៍បានជ្រាប នឹងមិនប្រព្រឹងអំពើរនានាដែលជាមូលហេតុអោយការប្រើឬការភ្ជាប់បណ្តាញទូរគមនាគមន៍របស់អ្នកបានប័ណ្ណអនុញ្ញាតផ្សេងនោះមិនអាចដំណើរការបានតាមប្រក្រតី។

នៅពេលដែលមានការផ្លស់ប្តូរកែប្រែបណ្តាញទូរគមនាគមន៍ដែលមានផលប៉ះពាល់ដល់ការប្រើឬភ្ជាប់បណ្តាញទូរគមនាគមន៍ អ្នកបានប័ណ្ណអនុញ្ញាតដែលមានបណ្តាញទូរគមនាគមន៍ត្រូវប្រកាសអោយបានជ្រាបចំពោះការផ្លស់ប្តូរកែប្រែនោះជាមុនក្នុងរយៈពេលដែលគួរសម ប៉ុន្តែត្រូវមិនតិចជាងប្រាំមួយខែ។

មាត្រា ២៩ អ្នកទទួលប័ណ្ណអនុញ្ញាតដែលជាម្ចាស់បណ្តាញទូរគមនាគមន៍ត្រូវបង្ហាញកិច្ចសន្យាការប្រើឬការភ្ជាប់បណ្តាញទូរគមនាគមន៍ជាទូទៅតាមវិធីការដែលគណៈកម្មការកំណត់

មាត្រា ៣០ ក្នុងករណីដែលសភាពការណ៍សេដ្ឋកិច្ចឬសង្គមមានការផ្លស់ប្តូរ ឬមានមូលហេតុណាមួយដែលអាចធ្វើអោយអត្រាតម្លៃនៃការប្រើឬការភ្ជាប់បណ្តាញទូរគមនាគមន៍ដែលកំណត់ក្នុងកិច្ចសន្យានោះមិនគួរសម បង្កអោយមានការចាញ់ប្រៀបរវាងអ្នកទទួលប័ណ្ណអនុញ្ញាតដែលជាមូលហេតុនាំអោយភាគីណាមួយត្រូវមានផ្ទុកលើសពីការគួរសម អ្នកទទួលប័ណ្ណអនុញ្ញាតដែលជាដៃគូសន្យាត្រូវសុំកែសម្រួលអត្រាតម្លៃនោះចំពោះគណៈកម្មការក៏បាន។ ក្នុងការអនុញ្ញាតអោយគណៈកម្មការគិតអំពីផលប៉ះពាល់ដែលមានចំពោះអ្នកប្រើសេវាផងដែរ។

មាត្រា ៣១ ដើម្បីប្រយោជន៍ក្នុងការរក្សាសន្តិសុខជាតិ ឬដើម្បីការពារគ្រោះធម្មជាតិដែលអាចខូចខាតជារួម ឬដើម្បីការដំណើរការជាប្រយោជន៍សាធារណៈ នៅពេលដែលរដ្ឋបាលអំពារនាវចំពោះគណៈកម្មការ អោយគណៈកម្មការដំណើរការដើម្បីអោយមានការប្រើឬភ្ជាប់បណ្តាញទូរគមនាគមន៍រវាងអ្នកទទួលប័ណ្ណអនុញ្ញាតនិងអង្គភាពរដ្ឋដែលទាក់ទង ក្នុងករណីដូចនេះអោយអ្នកទទួលប័ណ្ណអនុញ្ញាត អនុវត្តតាមបញ្ជារបស់គណៈកម្មការ។

## ជំពូក ៣
## ស្តង់ដាររបស់បណ្តាញទូរគមនាគមន៍និងឧបករណ៍

---

មាត្រា ៣២ អោយគណៈកម្មការមានអំណាចប្រកាសកំណត់ប្រភេទរបស់បណ្តាញទូរគមនាគមន៍ ម៉ាស៊ីនទូរគមនាគមន៍ឬឧបករណ៍ដែលប្រើក្នុងកិច្ចការទូរគមនាគមន៍ត្រូវមានស្តង់ដាផ្នែកបច្ចេកទេសតាមដែលបានកំណត់

គណៈកម្មការអាចប្រកាសកំណត់អោយឧបករណ៍ដែលប្រើក្នុងបណ្តាញទូរគមនាគមន៍ ម៉ាស៊ីនទូរគមនាគមន៍ ឬឧបករណ៍ដែលប្រើក្នុងកិច្ចការទូរគមនាគមន៍ប្រភេទខ្លះៗ ត្រូវបានការត្រួតពិនិត្យនិងធានាស្តង់ដាមុននាំមកប្រើប្រាស់ក្នុងការបំរើសេវាទូរគមនាគមន៍

មាត្រា ៣៣ អ្នកទទួលប័ណ្ណអនុញ្ញាតត្រូវថែរក្សា ជួសជុល និងកែសម្រួលបណ្តាញទូរគមនាគមន៍ ម៉ាស៊ីនទូរគមនាគមន៍និងឧបករណ៍ដែលប្រើក្នុងកិច្ចការទូរគមនាគមន៍ដែលអ្នកទទួលប័ណ្ណអនុញ្ញាតនាំមកប្រើក្នុងការបំរើសេវាទូរគមនាគមន៍ដើម្បីអោយការប្រើប្រាសប្រកបដោយប្រសិទ្ធិភាពនិងមានស្តង់ដាផ្នែកបច្ចេកទេសតាមដែលបានកំណត់ក្នុងប្រកាសតាមមាត្រា ៣២

មាត្រា ៣៤ អ្នកទទួលប័ណ្ណអនុញ្ញាតប្រភេទទីបីត្រូវមានវិស្វករដែលមានលក្ខណៈសម្បត្តិនិងចំនួនតាមដែលគណៈកម្មការបានកំណត់ដើម្បីបំពេញទូនាទីគ្រប់គ្រងការដំណើរការបំរើសេវាទូរគមនាគមន៍ ការបំពាក់ ត្រួតពិនិត្យ និងថែរក្សាបណ្តាញទូរគមនាគមន៍ ម៉ាស៊ីនទូរគមនាគមន៍ និងឧបករណ៍ដែលប្រើក្នុងកិច្ចការទូរគមនាគមន៍របស់អ្នកទទួលប័ណ្ណអនុញ្ញាតអោយស្របទៅតាមស្តង់ដាផ្នែកបច្ចេកទេស។

មាត្រា ៣៥ អោយការិយាល័យមានអំណាចទទួលធ្វើការពិនិត្យនិងធានាស្តង់ដារបស់ឧបករណ៍ដែលប្រើក្នុងបណ្តាញទូរគមនាគមន៍ ម៉ាស៊ីនទូរគមនាគមន៍ និងឧបករណ៍ដែលប្រើក្នុងកិច្ចការទូរគមនាគមន៍តាមប្រកាសរបស់គណៈកម្មការតាមមាត្រា ៣២ កថាខណ្ឌទីពីរ ឬករណីដែលមានការអំពាវនារពីបុគ្គលដែលមានបំណងនឹងអោយមានការពិនិត្យនិងធានាស្តង់ដា។

ការពិនិត្យនិងធានាស្តង់ដាតាមកថាខណ្ឌពីមួយ អោយស្របទៅតាមរបៀបដែលគណៈកម្មការបានកំណត់។

មាត្រា ៣៦ បុគ្គលណាមានបំណងចង់ធ្វើការពិនិត្យនិងធានាស្តង់ដាអោយបង្កើតជាអង្គភាពពិនិត្យនិងធានាស្តង់ដារបស់ឧបករណ៍ដែលប្រើក្នុងបណ្តាញទូរគមនាគមន៍ ម៉ាស៊ីនទូរគមនាគមន៍និងឧបករណ៍ដែលប្រើក្នុងកិច្ចការទូរគមនាគមន៍ ដែលត្រូវជាសហគ្រាសនិងត្រូវបានប័ណ្ណអនុញ្ញាតពីគណៈកម្មការ។

លក្ខណៈសម្បត្តិរបស់អ្នកសុំប័ណ្ណអនុញ្ញាត ការដាក់ពាក្យសុំប័ណ្ណអនុញ្ញាត ការចេញប័ណ្ណអនុញ្ញាត អាយុប័ណ្ណអនុញ្ញាត ការពន្យាប័ណ្ណអនុញ្ញាត តម្លៃនៃការចេញប័ណ្ណអនុញ្ញាតនិងការពន្យាប័ណ្ណអនុញ្ញាត អោយស្របទៅតាមគោលការណ៍ វិធីការ និងលក្ខណ្ឌដែលគណៈកម្មការបានកំណត់។

អង្គភាពពិនិត្យនិងធានាត្រូវមានអ្នកត្រួតពិនិត្យដែលមានលក្ខណៈសម្បត្តិនិងចំនួនតាមដែលគណៈកម្មការបានកំណត់។

ការអនុញ្ញាតអោយបង្កើតអង្គភាពពិនិត្យនិងធានា គណៈកម្មការនឹងកំណត់លក្ខណ្ឌនានាតាមការគួរសមក៏បាន។

ការទារថ្លៃសេវាពិនិត្យនិងធានាស្តង់ដារបស់អ្នកទទួលប័ណ្ណអនុញ្ញាតតាមកថាខណ្ឌទីមួយអោយស្របទៅតាមអត្រាដែលគណៈកម្មការកំណត់។

មាត្រា ៣៧ ក្នុងករណីដូចតទៅ អោយគណៈកម្មការមានអំណាចដកហូតប័ណ្ណអនុញ្ញាតបង្កើតអង្គភាពពិនិត្យនិងធានា

(១) អ្នកទទួលប័ណ្ណអនុញ្ញាតបង្កើតអង្គភាពពិនិត្យនិងធានាខ្វះខាតលក្ខណៈសម្បត្តិតាមដែលបានកំណត់ក្នុងប្រកាសតាមមាត្រា ៣៦ កថាខណ្ឌទីពីរ

(២) អង្គភាពពិនិត្យនិងធានាដំណើរការពិនិត្យ រាយការណ៍លទ្ធផលការពិនិត្យឬធានាដោយទុច្ចរិត

(៣) ការពិនិត្យ ការរាយការណ៍លទ្ធផលការពិនិត្យឬការធានាដំណើរការយឺតដោយគ្មានមូលហេតុគួរសម ជាមូលហេតុបង្កអោយអ្នកសុំការពិនិត្យទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរ

(៤) អង្គភាពពិនិត្យនិងធានាមានអ្នកពិនិត្យដែលមានលក្ខណៈសម្បត្តិឬមានចំនួនមិនគ្រប់តាមដែលគណៈកម្មការកំណត់

ការដកហូតប័ណ្ណអនុញ្ញាតតាមកថាខណ្ឌទីមួយមិនមែនជាមូលហេតុនាំអោយមានផលប៉ះពាល់ការធានាស្តង់ដាដែលអង្គភាពពិនិត្យនិងធានាបានដំណើរការកន្លងទៅមុននឹងត្រូវដកហូតប័ណ្ណអនុញ្ញាត។ លើកលែងតែការធានាស្តង់ដាដែលទិច្ចរិត ឬមិនត្រូវទៅតាមស្តង់ដាដែលគណៈកម្មការកំណត់ គណៈកម្មការអាចពិចារណាដកហូតការធានាស្តង់ដានោះបាន។

ករណីដែលបុគ្គលណារងការខូចខាតពីការធានាស្តង់ដាដែលត្រូវដកហូតតាមកថាខណ្ឌទីពីរ បើបុគ្គលនោះមិនបានរួមប្រព្រឹត្តិទុច្ចរិត អោយអង្គភាពពិនិត្យនិងធានាដែលត្រូវដកហូតប័ណ្ណអនុញ្ញាតមានកាតព្វកិច្ចត្រូវសងចំពោះភាពខូចខាតនោះ។

មាត្រា ៣៨ ករណីដែលបណ្តាញទូរគមនាគមន៍ ម៉ាស៊ីនទូរគមនាគមន៍ ឬឧបករណ៍នានារបស់អ្នកទទួលប័ណ្ណអនុញ្ញាតដំណើរការមិនបាន ដំណើរការខុសប្រក្រតី បង្កអោយមានការរំខានកិច្ចការទូរគមនាគមន៍ ឬមិនត្រូវទៅតាមស្តង់ដាដែលកំណត់ក្នុងប្រកាសដែលចេញតាមមាត្រា ៣២ ។ អោយមន្ត្រីសមត្ថកិច្ចមានអំណាចបញ្ជាអោយអ្នកទទួលប័ណ្ណអនុញ្ញាតកែសម្រួល ផ្លាស់ប្តូរ ឬផ្អាកការប្រើបណ្តាញទូរគមនាគមន៍ឬឧបករណ៍នោះបាន។

សេចក្តីតាមកថាខណ្ឌទីមួយអោយអនុវត្តជាមួយឧបករណ៍ដែលប្រើក្នុងកិច្ចការទូរគមនាគមន៍របស់អ្នកប្រើសេវាជាការអនុលោម។

## ជំពូក ៤
## សិទ្ធិរបស់អ្នកទទួលប័ណ្ណអនុញ្ញាត

---

មាត្រា ៣៩ ការដំណើរការបំរើសេវាទូរគមនាគមន៍ បើអ្នកទទួលប័ណ្ណអនុញ្ញាតមានមូលហេតុត្រូវបោះបង្គោលឬដាក់ខ្សែភ្លើង ដាក់លូ ឬបំពាក់ឧបករណ៍នានាដែលចាំបាច់ប្រើសិទ្ធិតាមមាត្រានេះ។ អោយអ្នកទទួលប័ណ្ណអនុញ្ញាតរៀបចំបង្កើតប្លង់របស់ទិសដៅ និងបន្ទាត់ព្រំដែនក្នុងការបោះបង្គោលដាក់ខ្សែភ្លើង ដាក់លូ ឬបំពាក់ឧបករណ៍នានា ស្នើជូនគណៈកម្មការដើម្បីឯកភាពមុនដំណើរការ។

នៅពេលដែលគណៈកម្មការបានឯកភាពតាមកថាខណ្ឌទីមួយហើយ អោយអ្នកទទួលប័ណ្ណអនុញ្ញាតមានសិទ្ធិដូចតទៅ

(១) ដាក់ខ្សែភ្លើង ឬបំពាក់ឧបករណ៍នានាក្នុងការបំរើសេវាទូរគមនាគមន៍ ត្រូវដាក់លើឬតាមសសរ ទុយោ ឬឧបករណ៍ដែលមានលក្ខណៈការប្រើប្រាស់ប្រហាក់ប្រហែលគ្នារបស់អ្នកទទួលប័ណ្ណអនុញ្ញាតផ្សេងឬរបស់អង្គភាពរដ្ឋឬរបស់អ្នកបំរើសេវាសាធារណៈផ្សេងបាន។ ដោយអ្នកទទួលប័ណ្ណអនុញ្ញាតផ្សេងឬអង្គភាពរដ្ឋនោះមិនអាចបដិសេធមិនអោយដំណើរការបានឡើយ ប៉ុន្តែអាចទារថ្លៃក្នុងការប្រើប្រាស់ប្រយោជន៍បានគួរសម។

(២) បោះឬបញ្ឈរសសរ ឬដាក់ខ្សែភ្លើង ដាក់ទុយោ ឬបំពាក់ឧបករណ៍នានាក្នុងការបំរើសេវាទូរគមនាគមន៍ក្នុងដីធ្លីដែលជាសម្បត្តិសាធារណៈរបស់ដែនដី ដោយត្រូវជូនដំណឹងអោយមន្ត្រីរដ្ឋដែលមានសិទ្ធិអំណាចគ្រប់គ្រងដីធ្លីនោះអោយបានជ្រាប់ជាមុនសិន ហើយត្រូវអនុវត្តតាមគោលការណ៍និងលក្ខណ្ឌដែលមន្ត្រីរដ្ឋដែលមានសិទ្ធិអំណាចនោះបានកំណត់។

(៣) បោះឬបញ្ឈរសសរ ឬដាក់ខ្សែភ្លើង ដាក់ទុយោ ឬបំពាក់ឧបករណ៍នានាក្នុងការបំរើសេវាទូរគមនាគមន៍ក្នុងដីធ្លីរបស់បុគ្គលផ្សេង ត្រូវឯកភាពជាមួយម្ចាស់ដីធ្លីនោះតាមមធ្យោបាយដែល គណៈកម្មការបានកំណត់

ករណីដែលអ្នកទទួលប័ណ្ណអនុញ្ញាតមិនអាចអនុវត្តបានតាមកថាខណ្ឌទីពីរបាន ដោយសារមិនបានការអនុញ្ញាត ឬមានការទារថ្លៃច្រើនលើសប្រក្រតី អ្នកទទួលប័ណ្ណអនុញ្ញាតអាចសុំអោយគណៈកម្មការពិចារណា។ បើគណៈកម្មការឃើញថាការអនុវត្តរបស់អ្នកទទួលប័ណ្ណ

អនុញ្ញាតជាករណីចាំបាច់ដែលមិនអាចជៀសវាងបាន និងមិនបង្កអោយមានការខូចខាតចំពោះអង្គភាពរដ្ឋ ម្ចាស់ឬអ្នកគ្រប់គ្រងដីធ្លីឬទ្រព្យនោះលើសពីការគួរសម។ អោយគណៈកម្មការមានអំណាចបញ្ជាក់ការប្រើដីធ្លីឬទ្រព្យដើម្បីកិច្ចការនោះអោយមន្ត្រីរដ្ឋដែលមានសិទ្ធិអំណាចថែរក្សាដីធ្លីឬទ្រព្យ ឬម្ចាស់ឬអ្នកគ្រប់គ្រងដីធ្លីឬទ្រព្យនានាបានជ្រាបជាមុនមិនតិចជាងសាមសិបថ្ងៃ ដោយត្រូវបញ្ជាក់កាលបរិច្ឆេត និងកិច្ចការដែលនិងប្រព្រឹត្តផងដែរ។

អ្នកបានដំណឹងតាមកថាខណ្ឌទីបីអាចដាក់ពាក្យបញ្ជាក់មូលហេតុដែលមិនគួរប្រើដីធ្លីឬទ្រព្យដើម្បីកិច្ចការនោះឬការដំណើរការនោះនឹងបង្កភាពខូចខាតយ៉ាងធ្ងន់ធ្ងរចំពោះការប្រើប្រយោជន៍លើ ដីធ្លីឬទ្រព្យជូនទៅគណៈកម្មការដើម្បីពិចារណាក្នុងសាមសិបថ្ងៃចាប់ពីថ្ងៃដែលបានដំណឹង ការពិចារណារបស់គណៈកម្មការជាទីបញ្ចប់។

នៅពេលដែលផុតកំណត់ពេលដែលគណៈកម្មការបានជូនដំណឹងតាមកថាខណ្ឌទីបី និងអ្នកទទួលប័ណ្ណអនុញ្ញាតបានបង់ថ្លៃការប្រើដីធ្លីនិងទ្រព្យតាមមាត្រា ៤០ ហើយ អោយអ្នកទទួលប័ណ្ណអនុញ្ញាតមានសិទ្ធិប្រើដីធ្លីឬទ្រព្យដើម្បីអនុវត្តតាមកថាខណ្ឌទីពីរបាន ប៉ុន្តែត្រូវស្របតាមគោលការណ៍ដែលគណៈកម្មការកំណត់ ដែលមិនបង្កភាពរំខានឬមានផលប៉ះពាល់ដល់ធម្មជាតិនិងមិនបង្កអោយការប្រើប្រាស់ប្រយោជន៍ដីធ្លីនោះថយចុះលើសពីការគួរសម។

មាត្រា ៤០ អ្នកទទួលប័ណ្ណអនុញ្ញាតត្រូវបង់ថ្លៃក្នុងការប្រើដីធ្លីតាមមាត្រា ៣៩ តាមចំនួនដែលគណៈកម្មការកំណត់។

ករណីដែលអ្នកមានទូនាទីថែរក្សាដីធ្លីឬទ្រព្យ ឬម្ចាស់ឬអ្នកគ្រប់គ្រងដីធ្លីឬទ្រព្យមិនយល់ព្រមទទួលថ្លៃតាមកថាខណ្ឌទីមួយ អោយអ្នកទទួលប័ណ្ណអនុញ្ញាតដាក់ប្រាក់ថ្លៃឈ្នួលចំពោះគណៈកម្មការតាមគោលការណ៍ដែលគណៈកម្មការកំណត់។

អ្នកទទួលប័ណ្ណអនុញ្ញាតឬម្ចាស់ដីធ្លីឬមន្ត្រីដែលថែរក្សាដីធ្លីដែលមិនពេញចិត្តចំពោះតម្លៃដែលគណៈកម្មការកំណត់តាមកថាខណ្ឌទីមួយ មានសិទ្ធិប្តឹងចំពោះតុលាការបាន

មាត្រា ៤១ នៅពេលដែលបានជូនដំណឹងអោយមន្ត្រីរដ្ឋដែលមានទូនាទីថែរក្សាដីធ្លីឬទ្រព្យឬម្ចាស់ឬអ្នកគ្រប់គ្រងដីធ្លីបានជ្រាបជាមុនតាមគោលការណ៍ដែលគណៈកម្មការកំណត់ហើយ។ អ្នកទទួលប័ណ្ណអនុញ្ញាតមានសិទ្ធិទាញខ្សែកាត់លើឬឆ្លងដីធ្លីដែលជាសម្បត្តិសាធារណៈឬរបស់បុគ្គលនានាបានដោយមិនចាំបាច់មានការឯកភាព។ បើការដំណើរការនោះមិនមែនជាមូលហេតុបង្កអោយមានផលប៉ះពាល់ដល់ការប្រើប្រាស់ប្រយោជន៍ដីធ្លីនោះ។

មន្ត្រីរបស់រដ្ឋដែលមានទូនាទីថែរក្សាដីធ្លីឬទ្រព្យ ឬម្ចាស់ឬអ្នកគ្រប់គ្រងដីធ្លីអាចជូនដំណឹងអោយអ្នកទទួលប័ណ្ណអនុញ្ញាតទាញខ្សែក្នុងបរិវេណដែលមិនមានផល់ប៉ះពាល់ដល់ការប្រើប្រាស់ដីធ្លីរបស់ខ្លួនបាន។ ហើយបើរងការខូចខាតពីការដំណើរការអោយមានសិទ្ធិទារថ្លៃខូចខាតពីអ្នកទទួលប័ណ្ណអនុញ្ញាតបាន។ ទាំងនេះត្រូវនាំយកសេចក្តីក្នុងមាត្រា ៣៩ និងមាត្រា ៤០ មកអនុវត្តជាការអនុលោម។

អោយនាំសេចក្តីក្នុងមាត្រានេះមកអនុវត្តជាមួយការដំណើរការតាមមាត្រា ៣៩ កថាខណ្ឌទីពីរ(១) ដោយអនុលោម

មាត្រា ៤២ អ្នកទទួលប័ណ្ណអនុញ្ញាតអាចចូលទៅក្នុងដីធ្លីដែលមានបណ្តាញទូរគមនាគមន៍ បង្គោល ខ្សែ ទុយោ ឬឧបករណ៍ដែលនៅក្នុងដីធ្លីនោះ ដើម្បីធ្វើការត្រួតពិនិត្យ ថែរក្សា ជួសជុលឬការពារគ្រោះថ្នាក់ឬភាពខូចខាតដែលអាចកើតឡើងបាន។ ដោយត្រូវជូនដំណឹងជាលាយលក្ខអក្សរទៅអោយអ្នកគ្រប់គ្រងដីធ្លីនោះបានជ្រាបជាមុនមិនតិចជាងសាមសិបថ្ងៃ។ លើកលេងតែមានករណីចាំបាច់ដែលត្រូវកែសម្រួលភាពខូចខាតដែលកើតឡើងនៅពេលនោះ អ្នកទទួលប័ណ្ណអនុញ្ញាតអាចចូលទៅក្នុងដីធ្លីដើម្បីដំណើរការកែសម្រួលបានភ្លាមៗ។

បើមានការខូចខាតកើតឡើងដោយសារតែការដំណើរការតាមកថាខណ្ឌទីមួយ អ្នករងការខូចខាតមានសិទ្ធិទារថ្លៃខូចខាតចំពោះការខូចខាតនោះពីអ្នកទទួលប័ណ្ណអនុញ្ញាតបាន។

មាត្រា ៤៣ ករណីដែលឧបករណ៍របស់អ្នកប្រើសេវាទូរគមនាគមន៍បង្កការរំខានផ្នែកទូរគមនាគមន៍ឬអាចបង្កអោយបណ្តាញទូរគមនាគមន៍ឬឧបករណ៍ដែលប្រើក្នុងការប្រកបកិច្ចការទូរគមនាគមន៍របស់អ្នកទទួលប័ណ្ណអនុញ្ញាតខូចខាត អោយអ្នកទទួលប័ណ្ណអនុញ្ញាតចេលលិខិតជូនដំណឹងអោយអ្នកប្រើសេវានោះផ្លាស់ប្តូរឬកែសម្រួលឧបករណ៍នោះក្នុងរយៈពេលគួរសម។

ករណីដែលអ្នកប្រើសេវាមិនដំណើរការតាមលិខិតជូនដំណឹងតាមកថាខណ្ឌទីមួយ ហើយការប្រើឧបករណ៍នោះមិនទាន់បង្កអោយមានការរំខានផ្នែកទូរគមនាគមន៍ ឬអាចបង្កអោយបណ្តាញទូរគមនាគមន៍ឬឧបករណ៍ដែលប្រើក្នុងការប្រកបកិច្ចការរបស់អ្នកទទួលប័ណ្ណអនុញ្ញាតខូចខាត។ អ្នកទទួលប័ណ្ណអនុញ្ញាតនឹងផ្អាកការអោយបំរើសេវាទូរគមនាគមន៍ជូនអ្នកប្រើសេវានោះជាបណ្តោះអាសន្នលុះដល់អ្នកប្រើសេវានឹងអនុវត្តអោយស្របទៅតាមលិខិតដែលបានជូនដំណឹងក៏បាន។

ករណីចាំបាច់បន្ទាន់ អ្នកទទួលប័ណ្ណអនុញ្ញាតនឹងផ្អាកការបំរសេវាទូរគមនាគមន៍នោះភ្លាមៗហើយជូនដំណឹងពេលក្រោយក៏បាន។

មាត្រា ៤៤ ហាមមិនអោយបុគ្គលណាធ្វើអោយខូចខាត បំផ្លាញ ធ្វើអោយអន់ថយ ធ្វើអោយគ្មានប្រយោជន៍ដែលបណ្តាញទូរគមនាគមន៍ បង្គោល ខ្សែ ទុយោ ឧបករណ៍ទទួលបញ្ជូន ឬឧបករណ៍នានាដែលប្រើក្នុងការបំរើសេវាទូរគមនាគមន៍ឬស្ថានីយ៍បំរើសេវាទូរគមនាគមន៍

ដើម្បីប្រយោជន៍នៃមាត្រានេះ គណៈកម្មការអាចប្រកាសកំណត់យន្តការការពាររបស់ទាំងនោះតាមកថាខណ្ឌទីមួយបានតាមការចាំបាច់។

## ជំពូក ៥
## សិទ្ធិរបស់អ្នកប្រើសេវា

---

មាត្រា ៤៥ បុគ្គលណារងការខូចខាតអំពីការបំរើសេវាទូរគមនាគមន៍របស់អ្នកទទួលប័ណ្ណអនុញ្ញាត បុគ្គលនោះមានសិទ្ធិប្តឹងចំពោះគណៈកម្មការបាន ដោយធ្វើជាលិខិតជូនចំពោះការិយាល័យ

លិខិតបណ្តឹងតាមកថាខណ្ឌទីមួយត្រូវបញ្ជាក់ការពិតយ៉ាងច្បាស់លាស់ ហើយបើមានឯកសារភ័ស្តុតាងដែលទាក់ទងនឹងករណីនោះក៏អោយរៀបបញ្ជូនជាមួយលិខិតដែរ។

ក្នុងអំឡុងពេលការពិចារណាពាក្យបណ្តឹងរបស់គណៈកម្មការ បើអ្នកបណ្តឹងទាមទារអោយគណៈកម្មការមានអំណាចពិចារណាកំណត់អោយអ្នកទទួលប័ណ្ណអនុញ្ញាតដំណើរការនានាដើម្បីកែសម្រួលជូនអ្នកបណ្តឹងជាបណ្តោះអាសន្នបាន។

មាត្រា ៤៦ អោយគណៈកម្មការពិចារក្តីបណ្តឹងអោយរួចស្រេចក្នុងសាមសិបថ្ងៃចាប់ពីថ្ងៃដែលបានទទួលលិខិតបណ្តឹង។ ដោយត្រូវអោយអ្នកដែលត្រូវបណ្តឹងមានឱកាសបញ្ជាក់អំពីការពិតនិងបង្ហាញភ័ស្តុតាងរបស់ខ្លួន។ ករណីដែលគណៈកម្មការឃើញថាអ្នកទទួលប័ណ្ណអនុញ្ញាតប្រព្រឹត្តិល្មើសច្បាប់ លក្ខណ្ឌការអនុញ្ញាត កិច្ចសន្យាការបំរើសេវា ឬមិនស្របទៅតាមស្តង់ដាការបំរើសេវាដ៏ល្អ អោយគណៈកម្មការមានអំណាចបញ្ជាអោយអ្នកទទួលប័ណ្ណអនុញ្ញាតដំណើរការកែសម្រួលអោយ ត្រឹមត្រូវក្នុងរយៈពេលដែលកំណត់។

មាត្រា ៤៧ ករណីដែលអ្នកប្រើសេវាឃើញថាអ្នកទទួលប័ណ្ណអនុញ្ញាតទារថ្លៃសេវាថ្លៃជាងអត្រាខ្ពស់បំផុតដែលគណៈកម្មការបានកំណត់តាមមាត្រា ៥៥ ឬខ្ពស់ជាងដែលទារពីអ្នកប្រើសេវាផ្សេងដែលប្រើសេវាដូចគ្នា ឬឃើញថាអ្នកទទួលប័ណ្ណអនុញ្ញាតទារថ្លៃសេវាដោយមិនត្រឹមត្រូវ។ អ្នកប្រើសេវាមានសិទ្ធិសុំជ្រាបអំពីពត៌មានទាក់ទងនិងការប្រើសេវារបស់ខ្លួនពីអ្នកទទួលប័ណ្ណអនុញ្ញាតបាន។

អ្នកបានប័ណ្ណអនុញ្ញាតត្រូវបញ្ជាក់ពត៌មានតាមកថាខណ្ឌទីមួយជូនអ្នកគ្រប់គ្រងក្នុងពេលវេលាគួរសម ប៉ុន្តែមិនលើសពីសាមសិបថ្ងៃចាប់ពីថ្ងៃដែលស្នើសុំ។ ហើយករណីដែលអ្នកប្រើសេវាស្នើសុំ អ្នកទទួលប័ណ្ណអនុញ្ញាតត្រូវរៀបចំធ្វើឯកសារធានាពត៌មានដែលត្រឹមត្រូវជូនអ្នកប្រើសេវាផងដែរ។ ដោយអាចគិតថ្លៃដើម្បីកិច្ចការនោះក៏បាន ប៉ុន្តែថ្លៃឈ្នួលត្រូវមិនខ្ពស់ពីការពិត ទាំងនេះ តាមគោលការណ៍ដែលគណៈកម្មការកំណត់។

មាត្រា ៤៨ ករណីដែលមានហេតុដែលត្រូវសង្ស័យថាអ្នកទទួលប័ណ្ណអនុញ្ញាតទារថ្លៃសេវាក្នុងលក្ខណៈមួយណាតាមមាត្រា ៤៧ កថាខណ្ឌទីមួយ អ្នកប្រើសេវាមានសិទ្ធិបណ្តឹងចំពោះគណៈកម្មការបានហើយយកសេចក្តីក្នុងមាត្រា ៤៥ និងមាត្រា ៤៦ មកអនុវត្តជាការអនុលោម។

ក្នុងការពិចារណារឿងបណ្តឹងតាមកថាខណ្ឌទីមួយ អោយអ្នកទទួលប័ណ្ណអនុញ្ញាតមានទូនាទីបញ្ជាក់ការពិតដើម្បីបញ្ជាក់ភាពត្រឹមត្រូវក្នុងការទារថ្លៃសេវា។

មាត្រា ៤៩ អ្នកប្រើសេវាមានសិទ្ធិនាំម៉ាស៊ីនទូរគមនាគមន៍របស់ខ្លួនមកប្រើក្នុងការទទួលសេវាពីអ្នកទទួលប័ណ្ណអនុញ្ញាតបាន។

ការទារថ្លៃក្នុងការនាំម៉ាស៊ីនទូរគមនាគមន៍របស់អ្នកប្រើសេវាមកប្រើជាមួយប្រព័ន្ធការបំរើសេវារបស់អ្នកទទួលប័ណ្ណអនុញ្ញាត អោយស្របទៅតាមអត្រានិងគោលការណ៍ដែលគណៈកម្មការកំណត់។

ក្នុងការបំរើសេវាទូរគមនាគមន៍អ្នកទទួលប័ណ្ណអនុញ្ញាតនឹងកំណត់លក្ខណ្ឌការបំរើសេវាដោយបង្គាប់អោយអ្នកប្រើសេវាត្រូវប្រើម៉ាស៊ីនរបស់អ្នកទទួលប័ណ្ណអនុញ្ញាតឬតាមដែលអ្នកទទួលប័ណ្ណអនុញ្ញាតកំណត់មិនបានឡើយ។ លើកលេងតែការប្រើសេវាទូរគមនាគមន៍ប្រភេទដែលមានភាពចាំបាច់ផ្នែកបច្ចេកទេសត្រូវប្រើម៉ាស៊ីនទូរគមនាគមន៍ដែលអ្នកទទួលប័ណ្ណអនុញ្ញាតកំណត់។ ទាំងនេះអ្នកទទួលប័ណ្ណអនុញ្ញាតនិងកំណត់លក្ខណ្ឌដូចនោះបាននៅពេលដែលគណៈកម្មការបានឯកភាពហើយថាការកំណត់ប្រភេទម៉ាស៊ីននោះមានមែនជាការផ្តាច់សិទ្ធិអ្នកប្រើសេវាដែលអាចរកម៉ាស៊ីនមកប្រើខ្លួនឯងបាន។ ក្នុងនេះ អ្នកទទួលប័ណ្ណអនុញ្ញាតនឹងបដិសេធការបំរើសេវាឬការភ្ជាប់ជាមួយប្រព័ន្ធចំពោះអ្នកប្រើសេវាមិនបានឡើយ។

មាត្រា ៥០ អោយគណៈកម្មការកំណត់យន្តការដើម្បីការពារអ្នកប្រើសេវាទាក់ទងនឹងពត៌មានផ្ទាល់ខ្លួន សិទ្ធិសេរីភាពក្នុងការទំនាក់ទំនងគ្នាតាមរយៈទូរគមនាគមន៍។

អោយអ្នកទទួលប័ណ្ណអនុញ្ញាតមានទូនាទីអនុវត្តតាមយន្តការដែលគណៈកម្មការកំណត់តាមកថាខណ្ឌទីមួយ

នៅពេលដែលឃើញថាបុគ្គលណាប្រព្រឹត្តល្មើសសិទ្ធិរបស់អ្នកប្រើសេវាការកថាខណ្ឌទីមួយ អោយអ្នកទទួលប័ណ្ណអនុញ្ញាតឬគណៈកម្មការដំណើរការដើម្បីផ្អាកសកម្មភាពនោះ ហើយជូនដំណឹងអោយអ្នកប្រើសេវាបានជ្រាបជាបន្ទាន់។

កិច្ចសន្យាបំរើសេវាទូរគមនាគមន៍

---

មាត្រា ៥១ កិច្ចសន្យារវាងអ្នកទទួលប័ណ្ណអនុញ្ញាតនិងអ្នកប្រើសេវាទូរគមនាគមន៍ និងលក្ខណ្ឌនានាដែលទាក់ទងនឹងការបំរើសេវាទូរគមនាគមន៍ដែលអ្នកទទួលប័ណ្ណអនុញ្ញាតនឹងកំណត់ រួមទាំងការកែសម្រួលកិច្ចសន្យាឬលក្ខណ្ឌនោះ ត្រូវបានការឯកភាពពីគណៈកម្មការជាមុនសិន។

កិច្ចសន្យានិងលក្ខណ្ឌដែលគណៈកម្មការនឹងឯកភាពបាន យ៉ាងហោចណាស់ត្រូវមាន

(១) មានការកំណត់ទាក់ទងនឹងទូនាទីនិងការទទួលខុសត្រូវរបស់អ្នកទទួលប័ណ្ណអនុញ្ញាតនិងអ្នកប្រើសេវាដែលច្បាស់លាស់និងយុត្តិធម៌។

(២) មានការកំណត់ទាក់ទងនឹងស្តង់ដាការបំរើសេវារបស់អ្នកទទួលប័ណ្ណអនុញ្ញាត

(៣) មានការកំណត់ទាក់ទងនឹងប្រភេទនិងវិសាលភាពនៃតម្លៃក្នុងការបំរើសេវាយ៉ាងគ្រប់គ្រាន់ យុត្តិធម៌។ហើយត្រូវមានការកំណត់ធានាការមិនទារថ្លៃក្រៅពីបានកំណត់ទុក

(៤) មានការកំណត់ដែលជាការរារាំងការប្រើប្រយោជន៍របស់អ្នកប្រើសេវា

(៥) មានការកំណត់ដែលមានលក្ខណៈរើសអើង បែងចែក ឬរារាំងអ្នកប្រើសេវាឬមិនយុត្តិធម៌ចំពោះភាគីណាមួយ

នៅពេលដែលអ្នកទទួលប័ណ្ណអនុញ្ញាតបានទទួលការឯកភាពក្នុងកិច្ចសន្យាឬលក្ខណ្ឌនានាហើយ អោយអ្នកទទួលប័ណ្ណអនុញ្ញាតមានសិទ្ធិនាំកិច្ចសន្យាឬលក្ខណ្ឌនោះទៅអនុវត្តជាមួយអ្នកប្រើសេវាបាន។

ដើម្បីប្រយោជន៍តាមមាត្រានេះ អោយគណៈកម្មការមានអំណាចប្រកាសកំណត់ស្តង់ដារបស់កិច្ចសន្យានិងលក្ខណ្ឌទាក់ទងនឹងការបំរើសេវាទូរគមនាគមន៍បាន។ ហើយនឹងកំណត់លើកលេងអោយកិច្ចសន្យាឬលក្ខណ្ឌក្នុងរឿងណាមិនត្រូវបានការឯកភាពពីគណៈកម្មការក៏បាន។

ករណីដែលមានច្បាប់ណាកំណត់គោលការណ៍ការធ្វើកិច្ចសន្យាទាក់ទងនឹងការបំរើសេវាទូរគមនាគមន៍ដើម្បីការពារអ្នកបរិភោគអោយអ្នកទទួលប័ណ្ណអនុញ្ញាតមានទូនាទីអនុវត្តតាម គោលការណ៍នៃច្បាប់នោះផងដែរ។

មាត្រា ៥២ អ្នកទទួលប័ណ្ណអនុញ្ញាតត្រូវរៀបចំអោយមានការផ្សព្វផ្សាយបែបកិច្ចសន្យានិងការកំណត់លក្ខណ្ឌក្នុងការបំរើសេវារបស់ខ្លួនជាទូទៅតាមវិធីការដែលគណៈកម្មការកំណត់ ហើយត្រូវបង្ហាញនៅកន្លែងដែលមើលឃើញងាយស្រួល នៅឯស្នាក់ការរបស់អ្នកទទួលប័ណ្ណអនុញ្ញាតដើម្បីអោយប្រជាជនទូទៅអាចពិនិត្យបាន។

មាត្រា ៥៣ ករណីដែលអ្នកទទួលប័ណ្ណអនុញ្ញាតបានផ្សាយពាណិជ្ជកម្មបញ្ជាក់ស្តង់ដាគុណភាពការបំរើសេវាទូរគមនាគមន៍របស់ខ្លួនទុក។ អោយជាទូនាទីរបស់អ្នកទទួលប័ណ្ណអនុញ្ញាតដែលត្រូវអនុវត្តអោយស្របទៅតាមការផ្សាយពាណិជ្ជកម្មនោះ។

បើអ្នកទទួលប័ណ្ណអនុញ្ញាតបំរើសេវាទូរគមនាគមន៍មិនស្របទៅតាមការផ្សាយពាណិជ្ជកម្ម អោយគណៈកម្មការមានអំណាចបញ្ជាអោយអ្នកទទួលប័ណ្ណអនុញ្ញាតដំណើរការកែសម្រួលអោយស្របទៅតាមដែលបានផ្សព្វផ្សាយបាន។

មាត្រា ៥៤ កិច្ចសន្យាឬកិច្ចព្រមព្រាងនានាទាក់ទងនឹងការប្រកបកិច្ចការនិងការបំរើសេវាទូរគមនាគមន៍តាមដែលគណៈកម្មការកំណត់ បើទទួលប័ណ្ណអនុញ្ញាតនឹងធ្វើជាមួយរដ្ឋបាលបរទេស អង្គការរវាងប្រទេស និងបុគ្គលឬសហគ្រាសដែលនៅក្រៅប្រទេស រួមទាំងការ

កែប្រែឬលុបចោលកិច្ចសន្យាឬកិច្ចព្រមព្រាងនោះ ត្រូវបានការឯកភាពពីគណៈកម្មការជាមុនសិន ទាំងនេះលើកលេងតែការទិញឬជួលតាមធម្មតា។

អ្នកទទួលប័ណ្ណអនុញ្ញាតត្រូវជូនច្បាប់ចម្លងកិច្ចសន្យាឬកិច្ចព្រមព្រាងដែលធ្វើជាមួយរដ្ឋបាលបរទេស អង្គការរវាងប្រទេស និងបុគ្គលឬសហគ្រាសដែលនៅក្រៅប្រទេសគ្រប់ច្បាប់តាមលក្ខណ្ឌដែលគណៈកម្មការបានកំណត់ក្នុងសាមសិបថ្ងៃចាប់ពីថ្ងៃដែលធ្វើកិច្ចសន្យាឬកិច្ចព្រមព្រាងនោះ។ លើកលេងតែកិច្ចសន្យាឬកិច្ចព្រមព្រាងដែលទាក់ទងនឹងការទិញឬជួល ឬកិច្ចសន្យាឬកិច្ចព្រមព្រាងដែលគណៈកម្មការកំណត់លើកលេងមិនចាំបាច់ជូនអោយគណៈកម្មការ។

ករណីដែលគណៈកម្មការឃើញថាកិច្ចសន្យាឬកិច្ចព្រមព្រាងណាបានធ្វើឡើងដោយមិនបានការឯកភាពតាមកថាខណ្ឌទីមួយ ឬមានការដំណើរការណាដែលខុសពីការឯកភាពរបស់គណៈកម្មការ អោយគណៈកម្មការមានអំណាចបញ្ជាអោយអ្នកទទួលប័ណ្ណអនុញ្ញាតដំណើរការកែសម្រួលតាមគោលការណ៍និងរយៈពេលដែលគណៈកម្មការកំណត់។ បើអ្នកទទួលប័ណ្ណអនុញ្ញាតមិនដំណើរការក្នុងរយៈពេលនោះ អោយចាត់ទុកថាជាមូលហេតុនាំអោយត្រូវដកហូតប័ណ្ណអនុញ្ញាត។

ជំពូក ៧

តម្លៃសេវាក្នុងកិច្ចការទូរគមនាគមន៍

---

មាត្រា ៥៥ អោយគណៈកម្មការប្រកាសកំណត់ប្រភេទនិងអត្រាខ្ពស់បំផុតរបស់តម្លៃសេវាដែលអ្នកទទួលប័ណ្ណអនុញ្ញាតនឹងទារពីអ្នកប្រើសេវាតាមលក្ខណៈនិងប្រភេទរបស់កិច្ចការទូរគមនាគមន៍ដែលបានការអនុញ្ញាតអោយប្រកបកិច្ចការ។

មាត្រា ៥៦ ការកំណត់អត្រាខ្ពស់បំផុតរបស់តម្លៃសេវាតាមតាត្រា ៥៥ ត្រូវ

(១) មានវិធិការគិតដែលច្បាស់លាស់

(២) ជាអត្រាដែលយុត្តិធម៌ចំពោះអ្នកទទួលប័ណ្ណអនុញ្ញាតនិងអ្នកប្រើសេវា

(៣) មិនមានលក្ខណៈជាការរើសអើង បែងចែក ឬរារាំងអ្នកប្រើសេវាឬបុគ្គលណាមួយ

មាត្រា ៥៧ អ្នកទទួលប័ណ្ណអនុញ្ញាតម្នាក់ៗ នឹងទារថ្លៃសេវាក្រៅពីកំណត់ឬលើសពីអត្រាខ្ពស់បំផុតដែលគណៈកម្មការកំណត់ក្នុងមាត្រា ៥៥ មិនបាន ហើយត្រូវមិនមែនជាការកំណត់ក្នុងលក្ខណៈដែលជាការរារាំងផ្នែលពាណិជ្ជកម្ម ដែលអាចជាការរារាំងការប្រកួតប្រជែងដោយយុត្តិធម៌។ ដោយត្រូវទារពីអ្នកប្រើសេវារបស់ខ្លួនក្នុងអត្រាមួយគ្នាសម្រាប់សេវាទូរគមនាគមន៍លក្ខណៈឬប្រភេទដូចគ្នា។

គណៈកម្មការអាចកំណត់អោយអ្នកទទួលប័ណ្ណអនុញ្ញាតចុះឬលើកលេងថ្លៃសេវាសម្រាប់សេវាផ្តល់ពត៌មាននិងចំនេះដឹងដើម្បីប្រយោជន៍ក្នុងការជំរុញចំនេះដឹងរបស់ប្រជាជនបានតាមគោលការណ៍ដែលគណៈកម្មការកំណត់។

មាត្រា ៥៨ អ្នកទទួលប័ណ្ណអនុញ្ញាតនឹងទារប្រាក់ធានាឬប្រាក់ផ្សេងៗដែលមានលក្ខណៈជាការបង់ទុកមុនមិនបានឡើយ។

ការល្មើសឬមិនអនុវត្តតាមមាត្រានេះរបស់អ្នកទទួលប័ណ្ណអនុញ្ញាត អោយចាត់ទុកថាជាការបង្កអោយមានភាពខូចខាតធ្ងន់ធ្ងរចំពោះប្រយោជន៍សាធារណៈ

បទបញ្ញត្តិមាត្រានេះអោយអនុវត្តជាមួយកិច្ចសន្យាបំរើសេវាទូរគមនាគមន៍ដែលបានធ្វើឡើងតាមព្រះរាជបញ្ញត្តិនេះ។

មាត្រា ៥៩ អ្នកទទួលប័ណ្ណអនុញ្ញាតត្រូវរៀបចំអោយមានការផ្សព្វផ្សាយអត្រាតម្លៃរបស់ខ្លួនជាទូទៅនិងត្រូវជូនដំណឹងអោយអ្នកប្រើសេវាគ្រប់រូបបានជ្រាបតាមវិធីការដែលគណៈកម្មការកំណត់ ហើយត្រូវបង្ហាញអត្រានោះនៅកន្លែងដែលងាយឃើញ នៅឯស្នាក់ការរបស់អ្នកទទួលប័ណ្ណអនុញ្ញាតដើម្បីអោយប្រជាជនទូទៅអាចពិនិត្យបាន។

ករណីដែលឃើញថាគួរសម គណៈកម្មអាចកំណត់អោយអ្នកទទួលប័ណ្ណអនុញ្ញាតត្រូវរៀបចំអោយមានប្រព័ន្ធបង្ហាញអត្រាតម្លៃសេវាជូនអ្នកប្រើសេវាបានជ្រាបជាមុនមុនការប្រើសេវាម្តងៗ នៅពេលដែលអ្នកប្រើសេវាត្រូវការក៏បាន ទាំងនេះ ដោយមិនគិតថ្លៃ។

មាត្រា ៦០ ករណីដែលសភាពការណ៍សេដ្ឋកិច្ចឬសង្គមមានការផ្លាស់ប្តូរ ឬមានមូលហេតុមួយណាដែលធ្វើអោយអត្រាតម្លៃខ្ពស់បំផុតរបស់តម្លៃសេវាដែលគណៈកម្មការកំណត់តាមមាត្រា ៥៥ មិនគួរសម បង្កអោយមានការបានប្រៀបចាញ់ប្រៀប ឬជាមូលហេតុនាំអោយអ្នកប្រើសេវាត្រូវទទួលបន្ទុកដោយមិនយុត្តិធម៌។ គណៈកម្មការអាចពិចារណាកែសម្រួលអត្រាតម្លៃសេវានោះបាន។

## ជំពូក ៨
## ការគ្រប់គ្រង

---

មាត្រា ៦១ ដើម្បីអនុវត្តអោយស្របទៅតាមព្រះរាជបញ្ញត្តិនេះ អោយមន្ត្រីសមត្ថកិច្ចមានអំណាចនឹងទូនាទីដូចតទៅ

(១) ចូលមកក្នុងអាគារឬកន្លែងប្រកបការរបស់អ្នកទទួលប័ណ្ណអនុញ្ញាតក្នុងអំឡុងពេលព្រះអាទិត្យរះដល់ព្រះអាទិត្យលិច ឬក្នុងម៉ោងធ្វើការរបស់កន្លែងនោះដើម្បីពិនិត្យកិច្ចការ សៀវភៅបញ្ជី ឯកសារភ័ស្តុតាងឬបតិមានដែលទាក់ទង រួមទាំងការប្រព្រឹត្តិនានាដែលអាចជាការល្មើសបទបញ្ញត្តិនេះ ឬមិនអនុវត្តតាមដែលកំណត់ក្នុងប័ណ្ណអនុញ្ញាត។

(២) មានលិខិតកក់ហៅអោយមកអោយពាក្យឬអោយបញ្ជូនឯកសារឬវត្ថុដើម្បីប្រកបការពិចារណា។

(៣) ពិនិត្យនិងបង្រួបបង្រួមការពិតហើយរាយការណ៍ជូនគណៈកម្មការក្នុងករណីដែលអ្នកទទួលប័ណ្ណអនុញ្ញាតបានប្រព្រឹត្តិល្មើសឬបង្កអោយមានការខូចខាតដោយសារមិនអនុវត្តតាមព្រះរាជបញ្ញត្តិនេះ ឬតាមដែលបានកំណត់ជាលក្ខណ្ឌការអនុញ្ញាត។

ក្នុងការបំពេញទូនាទីរបស់មន្ត្រីសមត្ថកិច្ចតាមកថាខណ្ឌទីមួយ អោយបុគ្គលដែលទាក់ទងជួយសម្រួលតាមគួរសម

នៅពេលដែលបានចូលទៅនិងបានពិនិត្យតាមកថាខណ្ឌទីមួយហើយដំណើរការមិនទាន់រួចស្រេច អាចបន្តនៅពេលដែលព្រះអាទិត្យលិចឬក្រៅម៉ោងធ្វើការរបស់កន្លែងនោះក៏បាន

ការបំពេញទូនាទីរបស់មន្ត្រីសមត្ថកិច្ចតាមមាត្រានេះត្រូវស្របទៅតាមគោលការណ៍ដែលគណៈកម្មការកំណត់ ទាំងនេះ ប្រកាសនោះត្រូវកំណត់តំណែងរបស់មន្ត្រីសមត្ថកិច្ចដែលនឹងប្រើអំណាចតាមមាត្រានេះ ហើយត្រូវកំណត់មូលហេតុនិងភាពចាំបាច់ដែលនឹងមានសិទ្ធិប្រើអំណាចតាមមាត្រានេះក្នុងករណីនីមួយៗផងដែរ។

ក្នុងការអនុវត្តតាមព្រះរាជបញ្ញត្តិនេះ អោយកម្មការនិងមន្ត្រីសមត្ថកិច្ចជាមន្ត្រីតាមច្បាប់ព្រហ្មទណ្ឌ

មាត្រា ៦២ ក្នុងការបំពេញទូនាទី មន្ត្រីសមត្ថកិច្ចត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណចំពោះអ្នកដែលទាក់ទង

អត្តសញ្ញាណប័ណ្ណមន្ត្រីសមត្ថកិច្ចអោយស្របទៅតាមទម្រង់ដែលគណៈកម្មការកំណត់

មាត្រា ៦៣ ករណីដែលមានហេតុអាសន្នឬមានការចាំបាច់ដើម្បីរក្សាសណ្តាប់ធ្នាប់របស់ប្រជាជន សន្តិសុខជាតិ ឬស្ថិរភាពសេដ្ឋកិច្ច ឬដើម្បីការពារប្រយោជន៍សាធារណៈ គណៈកម្មការអាចបញ្ជាអោយមន្ត្រីសមត្ថកិច្ចចូលទៅកាន់កាប់និងប្រើឧបករណ៍និងប្រដាប់ប្រដានានារបស់អ្នកទទួលប័ណ្ណអនុញ្ញាតដើម្បីដំណើរការឬប្រគល់អោយអង្គភាពរដ្ឋដំណើរការជំនួសជាបណ្តោះអាសន្ន ឬបញ្ជាអោយអ្នកទទួលប័ណ្ណអនុញ្ញាត ឬបុគ្គលិករបស់អ្នកទទួលប័ណ្ណអនុញ្ញាតអនុវត្តកិច្ចការមួយណាដើម្បីកិច្ចការនោះលុះដល់ហេតុអាសន្នឬភាពចាំបាច់នោះបានបញ្ចប់។

ក្នុងការអនុវត្តតាមកថាខណ្ឌទីមួយ បើមន្ត្រីសមត្ថកិច្ចបានបង្កអោយមានការខូចខាតចំពោះអ្នកទទួលប័ណ្ណអនុញ្ញាត អោយអ្នកទទួលប័ណ្ណអនុញ្ញាតមានសិទ្ធិទារសំណងសម្រាប់ការខូចខាតនោះពីការិយាល័យបាន។

## ជំពូក ៩

## ការបង្គាប់ផ្នែកការគ្រប់គ្រង

---

មាត្រា ៦៤ ករណីដែលប្រកដចំពោះលេខាធិការថាអ្នកទទួលប័ណ្ណអនុញ្ញាតល្មើសឬមិនអនុវត្តតាមមាត្រា ៩ កថាខណ្ឌទីប្រាំ មាត្រា ១១ មាត្រា ១២ កថាខណ្ឌទីពីរ ឬកថាខណ្ឌទីបី មាត្រា ១៣ កថាខណ្ឌទីពីរ មាត្រា ១៥ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ កថាខណ្ឌទីពីរ មាត្រា ២៧ មាត្រា ២៨ មាត្រា ២៩ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៤៥ កថាខណ្ឌទីបី មាត្រា ៤៦ មាត្រា ៤៩ មាត្រា ៥០ មាត្រា ៥១ មាត្រា ៥២ មាត្រា ៥៣ មាត្រា ៥៤ មាត្រា ៥៦ មាត្រា ៥៧ មាត្រា ៥៨ ឬ មាត្រា ៥៩ អោយលេខាធិការមានអំណាចបញ្ជាអោយអ្នកទទួលប័ណ្ណអនុញ្ញាតផ្អាក់សកម្មភាពដែលល្មើស ឬកែសម្រួល ឬអនុវត្តអោយត្រឹមត្រូវឬគួរសមក្នុងរយៈពេលដែលកំណត់ក៏បាន។

មាត្រា ៦៥ ករណីដែលអ្នកទទួលប័ណ្ណអនុញ្ញាតដែលបានទទួលបញ្ជាពីលេខាធិការតាមមាត្រា ៦៤ មិនពេញចិត្តក្នុងបទបញ្ជានោះអោយមានសិទ្ធិបណ្តឹងឧទ្ធរណ៍ចំពោះគណៈកម្មការក្នុងដប់ប្រាំថ្ងៃចាប់ពីថ្ងៃដែលបានទទួលបញ្ជានោះ។ ពាក្យកាត់ក្តីរបស់គណៈកម្មការជាទីបញ្ចប់។

មាត្រា ៦៦ ករណីដែលអ្នកទទួលប័ណ្ណអនុញ្ញាតមិនអនុវត្តតាមបទបញ្ជារបស់លេខាធិការតាមមាត្រា ៦៤ និងផុតកំណត់ពេលបណ្តឹងឧទ្ធរណ៍តាមមាត្រា ៦៥ ឬគណៈកម្មការបានកាត់ក្តីបញ្ជាក់តាមបទបញ្ជាលេខាធិការ។ នៅពេលដែលលេខាធិការបានមានលិខិតប្រមានហើយនៅមិនទាន់មានការអនុវត្តតាមបទបញ្ជានោះ។ អោយលេខាធិការពិចារណាកំណត់ប្រាក់ពិន័យតាមច្បាប់ស្តីពីវិធីអនុវត្តរាជការផ្នែកការគ្រប់គ្រង ដែលត្រូវមិនតិចជាងពីរម៉ឺនបាទក្នុងមួយថ្ងៃ។

ករណីដែលអ្នកទទួលប័ណ្ណអនុញ្ញាតនៅតែប្រងើយកន្តើយមិនអនុវត្តអោយត្រឹមត្រូវ ឬល្មើសបទបញ្ជាផ្អាក់ការប្រើប័ណ្ណអនុញ្ញាឬករណីដែលមានការខូចខាតធ្ងន់ធ្ងរចំពោះប្រយោជន៍សាធារណៈ អោយគណៈកម្មការមានអំណាចផ្អាក់ការប្រើឬដកហូតប័ណ្ណអនុញ្ញាតបាន។

ការកំណត់អោយបទល្មើសណាត្រូវផ្អាក់ឬដកហូតប័ណ្ណអនុញ្ញាត អោយស្របទៅតាមដែលគណៈកម្មការកំណត់។

ការកំណត់ទោស

---

មាត្រា ៦៧ អ្នកណាប្រកបកិច្ចការទូរគមនាគមន៍ដោមិនបានការអនុញ្ញាតឬប្រើរលកអាកាសក្នុងការប្រកបកិច្ចការទូរគមនាគមន៍ដោយមិនបានការអនុញ្ញាត ត្រូវមានទោសដូចតទៅ

(១) បើការល្មើសជាការប្រកបកិច្ចការដែលកំណត់អោយត្រូវមានប័ណ្ណអនុញ្ញាតប្រភេទទីមួយ ត្រូវពិន័យជាប្រាក់មិនលើសមួយសែនបាទ

(២) បើការល្មើសជាការប្រកបកិច្ចការដែលកំណត់អោយត្រូវមានប័ណ្ណអនុញ្ញាតប្រភេទទីពីរ ត្រូវផ្តន្ទាទោសមិនលើសពីពីរឆ្នាំ ឬពិន័យជាប្រាក់មិនលើសមួយលានបាទ ឬទាំងពីរ

(៣) បើការល្មើសជាការប្រកបកិច្ចការដែលកំណត់អោយត្រូវមានប័ណ្ណអនុញ្ញាតប្រភេទទីពីរ ត្រូវផ្តន្ទាទោសមិនលើសពីប្រាំឆ្នាំ ឬពិន័យជាប្រាក់មិនលើសដប់លានបាទ ឬទាំងពីរ

ករណីដែលតុលាការមានការកាត់ក្តីថាអ្នកដែលល្មើសមានកំហុសតាមព្រះរាជបញ្ញត្តិនេះ អោយតុលាការបញ្ជារឹបយកប្រដាប់ប្រដាឧបករណ៍ និងវត្ថុនានាដែលប្រើក្នុងកិច្ចការនោះទាំងអស់

មាត្រា ៦៨ អ្នកទទួលប័ណ្ណអនុញ្ញាតណាបង្រីកការបំរើសេវដោយមិនបានការអនុញ្ញាតតាមមាត្រា ១៤ ត្រូវផ្តន្ទាទោសមិនលើសពីបី ឬពិន័យជាប្រាក់មិនលើសប្រាំមួយសែនបាទ ឬទាំងពីរ

មាត្រា ៦៩ ៦៨ អ្នកទទួលប័ណ្ណអនុញ្ញាតណាល្មើសមាត្រា ២១ ត្រូវផ្តន្ទាទោសមិនលើសពីបីឆ្នាំ ឬពិន័យជាប្រាក់មិនលើសប្រាំមួយសែនបាទ ឬទាំងពីរ។ ហើយក្នុងករណីដែលប្រព្រឹត្តិល្មើសដដែលត្រូវផ្តន្ទាទោសជាទ្វេដង។

មាត្រា ៧០ អ្នកបានប័ណ្ណអនុញ្ញាតណាមិនអនុវត្តតាមបទបញ្ជារបស់គណៈកម្មការតាមមាត្រា ៣១ ត្រូវផ្តន្ទាទោសមិនលើសពីបីឆ្នាំ ឬពិន័យជាប្រាក់មិនលើសប្រាំមួយសែនបាទ ឬទាំងពីរ

មាត្រា ៧១ អ្នកណាធ្វើការពិនិត្យឬធានាស្តង់ដាឧបករណ៍ដែលប្រើក្នុងការទូរគមនាគមន៍ដោយមានបានការអនុញ្ញាតតាមមាត្រា ៣៦ ត្រូវផ្តន្ទាទោសមិនលើសពីបីខែ ឬពិន័យជាប្រាក់មិនលើសប្រាំម៉ឺនបាទ ឬទាំងពីរ

អ្នកបានប័ណ្ណអនុញ្ញាតអោយបង្កើតអង្គភាពត្រួតពិនិត្យនិងធានាស្តង់ដារបស់ឧបករណ៍ដែលប្រើក្នុងការទូរគមនាគមន៍។ អ្នកណាមិនអនុវត្តតាមលក្ខណ្ឌដែលគណៈកម្មការកំណត់តាមមាត្រា ៣៦ កថាខណ្ឌទីបួន ត្រូវពិន័យជាប្រាក់មិនលើសមួយម៉ឺនបាទ។

មាត្រា ៧២ អ្នកណាល្មើសមាត្រា ៤៤ កថាខណ្ឌទីមួយ ប៉ុន្តែមិនមានផលបង្កអោយប្រព័ន្ធទូរគមនាគមន៍ជាប់គាំង ត្រូវផ្តន្ទាទោសមិនលើសពីប្រាំមួយខែ ឬពិន័យជាប្រាក់មិនលើសមួយសែនបាទ ឬទាំងពីរ

មាត្រា ៧៣ អ្នកណាធ្វើអោយខូចខាត បំផ្លាញ ធ្វើអោយអន់ថយ ធ្វើអោយគ្មានប្រយោជន៍ដែលសញ្ញា ពោង ឬអ្វីផ្សេងៗដែលកំណត់ដើម្បីការពារប្រព័ន្ធទូរគមនាគមន៍តាមយន្តការដែលគណៈកម្មការកំណត់តាមមាត្រា ៤៤ កថាខណ្ឌទីពីរ ត្រូវផ្តន្ទាទោសមិនលើសពីពីរឆ្នាំ ឬពិន័យជាប្រាក់មិនលើសបួនសែនបាទ ឬទាំងពីរ

មាត្រា ៧៤ អ្នកណាប្រព្រឹត្តិដោយវិធីនានាដើម្បីលួចស្តាប់ ប្រើប្រយោជន៍ ឬបង្ហាញសារពត៌មាន ឬពត៌មាននានាដែលមានការទំនាក់ទំនងតាមរយៈទូរគមនាគមន៍ដោយមិនស្របច្បាប់ ត្រូវផ្តន្ទាទោសមិនលើសពីពីរឆ្នាំ ឬពិន័យជាប្រាក់មិនលើសបួនសែនបាទ ឬទាំងពីរ

មាត្រា ៧៥ អ្នកណាមិនជួយសម្រួលចំពោះមន្ត្រីសមត្ថកិច្ចដែលបំពេញទូនាទីតាមមាត្រា ៦១ កថាខណ្ឌទីមួយ (១) ឬមិនមកអោយពាក្យ ឬមិនបញ្ជូនឯកសារឬវត្ថុនានាតាមដែលមន្ត្រីសមត្ថកិច្ចមានលិខិតកក់ហៅតាមមាត្រា ៦១ កថាខណ្ឌទីមួយ (២) ត្រូវផ្តន្ទាទោសមិនលើសពីមួយខែ ឬពិន័យជាប្រាក់មិនលើសមួយម៉ឺនបាទ ឬទាំងពីរ

មាត្រា ៧៦ អ្នកណារារាំងការបំពេញទូនាទីរបស់មន្ត្រីសមត្ថកិច្ចតាមមាត្រា ៦៣ កថាខណ្ឌទីមួយ ត្រូវផ្តន្ទាទោសមិនលើសពីប្រាំមួយខែ ឬពិន័យជាប្រាក់មិនលើសមួយសែនបាទ ឬទាំងពីរ

មាត្រា ៧៧ បណ្តាបទល្មើសតាមព្រះរាជបញ្ញត្តិនេះដែលមានអត្រាផ្តន្ទាទោសមិនលើសប្រាំមួយខែ អោយគណៈកម្មការមានអំណាចប្រៀបធៀបពិន័យជាប្រាក់បាន។ ក្នុងនេះគណៈកម្មការអាចតែងតាំងគណៈអនុកម្មការដើម្បីដំណើរការជំនួសបាន។ ដោយនឹងកំណត់គោលការណ៍ក្នុងការប្រៀបធៀបឬកំណត់លក្ខណ្ឌក្នុងការបំពេញទូនាទីជំនួសគណៈអនុកម្មការក៏បាន។

ករណីដែលបទល្មើសប្រាកដចំពោះមន្ត្រីសើបអង្កេត ហើយជនល្មើសយល់ព្រមអោយប្រៀបធៀប អោយមន្ត្រីសើបអង្កេតជូនរឿងទៅគណៈកម្មការដើម្បីដំណើរការពិចារណាប្រៀបធៀបពិន័យជាបន្ទាន់។

នៅពេលដែលជនល្មើសបានបង់ប្រាក់ពិន័យហើយ អោយចាត់ទុកថាជាទីបញ្ចប់តាមច្បាប់ព្រហ្មទណ្ឌវិធីពិចារណាក្តីព្រហ្មទណ្ឌ

មាត្រា ៧៨ ករណីដែលជនល្មើសដែលត្រូវទទួលទោសតាមព្រះរាជបញ្ញត្តិនេះជាសហគ្រាស អោយកម្មការអ្នកគ្រប់គ្រង អ្នកចាត់ការ ឬបុគ្គលដែលទទួលខុសត្រូវក្នុងការដំណើរការរបស់សហគ្រាសនោះ ត្រូវផ្តន្ទាទោសតាមដែលបានបញ្ញត្តិទុកសម្រាប់កំហុសនោះៗ។ លើកលេងតែអាចបញ្ជាក់បានថាការល្មើសនោះធ្វើដោយខ្លួនមិនដឹងមិនលឺឬយល់ព្រមផង។

## អន្តរប្បញ្ញត្តិ

---

មាត្រា ៧៩ អោយគណៈកម្មការដំណើរការចេញប័ណ្ណអនុញ្ញាតប្រកបកិច្ចការទូរគមនាគមន៍តាមព្រះរាជបញ្ញត្តិនេះជូនអោយការទំនាក់ទំនងនៃប្រទេសថៃនិងអង្គការទូរស័ព្ទនៃប្រទេសថៃតាមលក្ខណៈនិងប្រភេទរបស់ការប្រកបកិច្ចការ វិសាលភាពការបំរើសេវា រួមទាំងសិទ្ធិនានាក្នុងការបំរើសេវាទូរគមនាគមន៍ដែលនៅក្នុងការទទួលខុសត្រូវរបស់ការទំនាក់ទំនងនៃប្រទេសថៃនិងអង្គការទូរស័ព្ទនៃប្រទេសថៃតាមដែលមាននៅក្នុងថ្ងៃដែលព្រះរាជបញ្ញត្តិនេះចូលជាធរមាន។ ទាំងនេះត្រូវមិនលើសពីមួយរយប៉ែតសិបថ្ងៃចាប់ពីថ្ងៃដែលគណៈកម្មការប្រកាសកំណត់គោលការណ៍ការអនុញ្ញាតតាមមាត្រា ៨

ក្នុងការចេញប័ណ្ណអនុញ្ញាតតាមកថាខណ្ឌទីមួយ អោយគណៈកម្មការកំណត់លក្ខណ្ឌទាក់ទងនឹងការប្រកបកិច្ចការរបស់ការទំនាក់ទំនងនៃប្រទេសថៃនិងអង្គការទូរស័ព្ទនៃប្រទេសថៃតាមការគួរសម។ ដោយគិតអំពីប្រយោជន៍របស់ប្រជាជនដែលប្រើសេវា និងការអភិវឌ្ឍដើម្បីអោយមានការសេវាដែលមានគុណភាពនិងប្រសិទ្ធិភាពឬការនានា ដើម្បីអោយបានជោគជ័យតាមព្រះរាជបញ្ញត្តិនេះ។

អោយការទំនាក់ទំនងនៃប្រទេសថៃនិងអង្គការទូរស័ព្ទនៃប្រទេសថៃ ជូនដំណឹងពត៌មានដែលទាក់ទងនឹងការប្រកបកិច្ចការទូរគមនាគមន៍អោយគណៈកម្មការបានជ្រាបក្នុងសាមសិបថ្ងៃចាប់ពីថ្ងៃដែលព្រះរាជបញ្ញត្តិនេះចូលជាធរមាន។

ក្នុងអំឡុងពេលដែលមិនទាន់បានប័ណ្ណអនុញ្ញាតតាមកថាខណ្ឌទីមួយ ការទំនាក់ទំនងនៃប្រទេសថៃនិងអង្គការទូរស័ព្ទនៃប្រទេសថៃបន្តប្រកិច្ចការទូរគមនាគមន៍បាន។

មាត្រា ៨០ ក្នុងការប្រកបកិច្ចការទូរគមនាគមន៍របស់ការទំនាក់ទំនងនៃប្រទេសថៃ ឬអង្គការទូរស័ព្ទនៃប្រទេសថៃតាមមាត្រា ៧៩ ។ បើអង្គភាពនោះបានមានការអោយអនុញ្ញាតសម្បទាន ឬកិច្ចសន្យាជូនអ្នកណាដែលជាអ្នកប្រកបកិច្ចការទូរគមនាគមន៍នៅហើយមុនថ្ងៃដែលព្រះរាជបញ្ញត្តិនេះចូលជាធរមាន។ អោយអ្នកទទួលប័ណ្ណអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះនៅមានសិទ្ធិប្រកបកិច្ចការទូរគមនាគមន៍តាមវិសាលភាព និងសិទ្ធិដែលមានតាមដែលបានការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះបន្ត លុះដល់ការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះបានបញ្ចប់។

ការប្រកបកិច្ចការទូរគមនាគមន៍របស់អ្នកបានការអនុញ្ញាត សម្បទាន ឬកិច្ចសន្យាតាមកថាខណ្ឌទីមួយ ត្រូវស្របទៅតាមព្រះរាជបញ្ញត្តិនេះ និងតាមលក្ខណ្ឌដែលគណៈកម្មារកំណត់លើក្របខណ្ឌការប្រកួតប្រជែងដោយសេរីនិងយុត្តិធម៌។ ក្នុងនេះអោយចាតទុកថាអ្នកនោះមានសិទ្ធិនិងទទួលខុសត្រូវដូចគ្នានឹងអ្នកទទួលប័ណ្ណអនុញ្ញាតតាមព្រះរាជបញ្ញត្តិនេះដែរ។ ហើយការល្មើសនានាតាមព្រះរាជបញ្ញត្តិនេះ អោយចាត់ទុកថាជាមូលហេតុនាំអោយគណៈកម្មការមានអំណាចដក់ហូតប័ណ្ណអនុញ្ញាតបាន។ បើជាការប្រព្រឹត្តរបស់អ្នកបានការអនុញ្ញាត សម្បទាន ឬកិច្ចសន្យាអោយគណៈកម្មការមានអំណាចបញ្ជដកហូតការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះបាន។

ការឯកភាពកែប្រែលក្ខណ្ឌការអនុញ្ញាត សម្បទាន ឬកិច្ចសន្យា ដោយមិនមែនជាការកាត់បន្ថយឬរារាំងសិទ្ធិក្នុងការប្រកបកិច្ចការទូរគមនាគមន៍តាមរយៈពេលដែលនៅសល់នៃការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះ មិនអោយចាត់ទុកថាជាការប្រព្រឹត្តិដែលមានផលប៉ះពាល់នៃការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះ។

ករណីដែលអ្នកបានការអនុញ្ញាត សម្បទាន ឬកិច្ចសន្យាណាធ្វើការឯកភាពជាមួយការទំនាក់ទំនងនៃប្រទេសថៃឬអង្គការទូរស័ព្ទនៃប្រទេសថៃ ដើម្បីប្តូរការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះ ជាការបានប័ណ្ណអនុញ្ញាតតាមព្រះរាជបញ្ញត្តិនោះ អោយគណៈកម្មការដំណើរការចេញប័ណ្ណអនុញ្ញាតអោយអ្នកបានការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះ។ ដោយអោយបានទទួលសិទ្ធិប្រកបកិច្ចការទូរគមនាគមន៍តាមវិសាលភាពការបំរើសេវាចាស់ដែលភាគីទាំងពីរបានឯកភាពគ្នានិងតាមរយៈពេលដែលនៅសល់នៃការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះ។ ទាំងនេះ ទ្រឹមដែលមិនជំទាស់ឬទាស់នឹងបទបញ្ញត្តិនៃព្រះរាជបញ្ញត្តិនេះ។ ការចេញប័ណ្ណអនុញ្ញាតអោយនាំមាត្រា ៧៩ មកអនុវត្តជាអនុលោម។

អោយនាំសេចក្តីក្នុងមាត្រានេះមកអនុវត្តជាមួយអ្នកបានការអនុញ្ញាត សម្បទាន ឬកិច្ចសន្យាពីអង្គភាពរដ្ឋផ្សេងៗ ដែលមាននៅក្នុងថ្ងៃដែលព្រះរាជបញ្ញត្តិនេះចូលជាធរមានជាអនុលោម។

មាត្រា ៨១ នៅពេលដែលគណៈកម្មការបានប្រកាសកំណត់គោលការណ៍ការអនុញ្ញាតតាមមាត្រា ៨ អោយអ្នកដែលដំណើរការអោយបំរើសេវាទូរគមនាគមន៍ដោយស្របតាមច្បាប់ដែលធ្វើនៅមុនមានប្រកាសមិនតិចជាងមួយរយម្ភៃថ្ងៃនិងមិននៅក្រោមបង្គាប់របស់មាត្រា ៧៩ និងមាត្រា ៨០ បើមានបំណងនឹងអោយបំរើសេវាបន្ត ត្រូវដាក់ពាក្យសុំប័ណ្ណអនុញ្ញាតតាមព្រះរាជបញ្ញត្តិនេះក្នុងកៅសិបថ្ងៃចាប់ពីថ្ងៃដែលគណៈកម្មការប្រកាសកំណត់។ ហើយក្នុងអំឡុងពេលនោះអោយនៅតែអោយបំរើសេវាទូរគមនាគមន៍បន្តទៅបាន។ ទាំងនេះ គណៈកម្មការត្រូវពិចារណាពាក្យសុំប័ណ្ណអនុញ្ញាតអោយរួចស្រេចក្នុងកៅសិបថ្ងៃចាប់ពីថ្ងៃដែលបានទទួលពាក្យ។

អោយនាំសេចក្តីតាមកថាខណ្ឌទីមួយមកអនុវត្តជាមួយគណៈកម្មការមានប្រកាសកំណត់លក្ខណៈនិងប្រភេទរបស់កិច្ចការទូរគមនាគមន៍បន្ថែមក្រោយពីប្រកាសតាមកថាខណ្ឌទីមួយជាអនុលោម

អ្នកទទួលព្រះប្រមរាជរាជឱង្ការ

វរៈសេនីទោ ថាក់ស៊ិន ឈិនណៈវ័ត

នាយករដ្ឋមន្ត្រី

<u>កត់សំគាល់:</u> មូលហេតុក្នុងការប្រកាសអោយប្រើព្រះរាជបញ្ញត្តិនេះ គឺ ដោយព្រះរាជបញ្ញត្តិរៀបចំអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ព.ស.២៥៤៣ ដែលជាច្បាប់ដែលបង្កើតឡើងអោយស្របទៅតាមមាត្រា ៤០ នៃរដ្ឋធម្មនុញ្ញនៃរាជាណាចក្រថៃ បានបញ្ញត្តិអោយចាត់តាំងគណៈកម្មការកិច្ចការផ្សាយសំឡេងនិងកិច្ចការទូរទស្សន៍ជាតិ និងគណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិជាអង្គការសេរី។ មានទួនាទីរៀបចំរលកអាកាសនិងគ្រប់គ្រងការប្រកបកិច្ចការវិទ្យុសំឡេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍។ ដោយអោយគណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិមានអំណាចក្នុងការអនុញ្ញាតនិងគ្រប់គ្រងការប្រកបកិច្ចការទូរគមនាគមន៍ និងអោយមានការព្រាងច្បាប់ស្ដីពីការប្រកបកិច្ចការទូរគមនាគមន៍ដែរ។ ដូច្នេះ ដើម្បីអោយស្របទៅតាមច្បាបនោះ ប្រកបជាមួយការប្រកបកិច្ចការទូរគមនាគមន៍បានកំណត់គោលការណ៍អោយមានការអនុញ្ញាត ទើបបានលុបច្បាប់ស្ដីពីទូរលេខនិងទូរស័ព្ទចោល ដើម្បីអោយស្របទៅជាមួយច្បាប់នោះ ទើបចាំបាច់ត្រូវព្រាងព្រះរាជបញ្ញត្តិនេះ។

This translated version is prepared with the sole purpose of facilitating the comprehension of foreign participants in the telecommunication rules and regulations and shall not in any event or by any reason be construed or interpreted as having effect in substitution for supplementary to the Thai version thereof. If its translation to other languages is in contrary to Thai version, the latter shall prevail.
Please note that the translation has not been subjected to an official review by the Office of the National Broadcasting and Telecommunications Commission. The Office of NBTC, accordingly, shall not undertake any responsibility for its accuracy, nor be held liable for any loss or damages arising from or in connection with its use.